វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីការប្រែសើរឡើង
Working Together for Positive Change

ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជាឆ្នាំ ២០១៥



ភ្នំពេញ, កម្ពុជា

ខែ កញ្ញា ឆ្នាំ ២០១៥

ការបោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស

ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជាឆ្នាំ ២០១៤
កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែកញ្ញា ឆ្នាំ ២០១៥
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
អ្នកសរសេរដោយ៖ មជ្ឈមណ្ឌលស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង
វិភាគទិន្នន័យដោយ៖ លោកស្រី នេត ចណ្ណា មន្ត្រីគ្រប់គ្រងព័ត៌មានភូមិសាស្ត្រ និងទិន្នន័យ
រចនាអត្ថបទដោយ៖ លោក ភួន ឃូ មន្ត្រីព័ត៌មាន និងការបោះពុម្ពផ្សាយ

អាសយដ្ឋាន៖ លេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន
រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ៖ ២២៩៥, រាជធានីភ្នំពេញ-៣
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh
គេហទំព័រ៖ www.ngoforum.org.kh

សេចក្តីបញ្ជាក់៖

ទស្សនៈបង្ហាញក្នុងរបាយការណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវគេដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវគេអោយតម្លៃ។

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, ខែកញ្ញា ឆ្នាំ ២០១៥**

សេចក្តីថ្លែងអំណរគុណ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សូមថ្លែងអំណរគុណចំពោះបុគ្គលិក និងអង្គការទាំងអស់ដែលបានជួយដល់ផ្នែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង(RAC) នៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ក្នុងការចងក្រងទិន្នន័យសំរាប់បង្ហាញជូនក្នុងរបាយការណ៍នេះ។ យើងខ្ញុំសូមអរគុណជាពិសេសចំពោះអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយក្នុងការចូលរួមយ៉ាងពេញលេញក្នុងកិច្ចដំណើរការប្រមូលទិន្នន័យ មានជាអាទិ៍ សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC) សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស(LICADHO) អង្គការរក្សាការពារសិទ្ធិមនុស្សនៃកម្ពុជា(Vigilance) សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្សនិងអភិឌ្ឍន៍(KKKHRDA) មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍(CLEC) ក្រុមការងារពិសេសសិទ្ធិលំនៅឋាន(HRTF) អង្គការស្រាវជ្រាវជាតិកម្ពុជា(CNRO) និងសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) ក៏ដូចជា អាជ្ញាធរថ្នាក់ខេត្តទាំងអស់ដែលបានផ្តល់ការគាំទ្រក្នុងអំឡុងពេលប្រមូលនិងផ្ទៀងផ្ទាត់ទិន្នន័យនៅមូលដ្ឋាន។ ផ្នែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង (RAC) សូមអរគុណចំពោះបណ្តាអង្គការនិងតំណាងសហគមន៍ទាំងឡាយដែលបានផ្តល់ព័ត៌មាន។ របាយការណ៍នេះ មិនអាចសម្រេចបានទេបើគ្មានការជួយជ្រោមជ្រែងនិងគាំទ្រពីសំណាក់លោក/លោកស្រី។

ជាមួយគ្នានេះ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សូមថ្លែងអំណរគុណចំពោះគណៈកម្មាធិការស្រាវជ្រាវ ក្នុងការផ្តល់នូវមតិយោបល់លើចំណុចខ្វះខាតនានា ក៏ដូចជាធាតុចូលសំខាន់ៗសំរាប់កែលម្អរបាយការណ៍នេះ ឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចទទួលយកបាន មុនពេលដាក់ឲ្យប្រើប្រាស់ជាសាធារណៈ។ យើងខ្ញុំ សូមអរគុណជាពិសេស ចំពោះអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរាជរដ្ឋាភិបាលដែលជាគណៈកម្មាការធិការស្រាវជ្រាវ មានដូចជា ក្រសួង

បរិស្ថាន អង្គការស្តារកម្ពុជា(Star Kampuchea) មជ្ឈមណ្ឌលសំរាប់ការរិភាគបញ្ហាអភិវឌ្ឍន៍(ADIC) សមាគមការពារសិទ្ធមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR) មហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លីនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

មាតិកា

អក្សរកាត់ iii
និយមន័យបច្ចេកសព្ទ v

១. សេចក្តីផ្តើម vii
២. គោលបំណងនៃរបាយការណ៍ ១
៣. យន្តការដោះស្រាយវិវាទ ២
៤. វិធីសាស្ត្រ ៦
៤.១ លក្ខណៈវិនិច្ឆ័យកំណត់ករណីវិវាទដីធ្លី ៦
៤.២ ការប្រមូលទិន្នន័យ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីវិវាទដីធ្លី ៧
៤.៣ ឧបករណ៍ប្រើប្រាស់ក្នុងការវិភាគស្ថិតិ ៨
៤.៤ ដែនកំណត់នៃវិធីសាស្ត្រ ៨

៥. លទ្ធផលនៃការវិភាគទិន្នន័យ ៩
៥.១ វិវាទដីធ្លីគិតតាមឆ្នាំ ៩
៥.២ វិវាទដីធ្លី និងទីកន្លែងមានវិវាទ ១៣
៥.២.១ ទីតាំងនៃវិវាទដីធ្លីនៅរាជធានីភ្នំពេញ ១៤
៥.២.២ ទីតាំងនៃវិវាទដីធ្លីនៅខេត្តរតនគិរី ១៧
៥.៣ ករណីវិវាទដីធ្លីដែលត្រូវបានដោះស្រាយតាមឆ្នាំ ២០
៥.៤ ដំណោះស្រាយករណីវិវាទដីធ្លី ២៣
៥.៤.១ ស្ថាប័នទទួលពាក្យបណ្តឹង ២៣
៥.៤.២ ដំណើរការដោះស្រាយវិវាទ ២៨
៥.៤.៣ ស្ថាប័នដែលដោះស្រាយវិវាទដីធ្លីក្នុងឆ្នាំ២០១៥ ..... ៣៥
៥.៥ គ្រួសារដែលរងផលប៉ះពាល់ពីវិវាទដីធ្លី ៤១
៥.៦ ប្រភេទដីដែលមានវិវាទ ៤៥
៥.៧ មូលហេតុនៃវិវាទដីធ្លី ៤៩
៥.៨ ឯកសារ និង វិធីសាស្ត្រដែលប្រើប្រាស់ដោយភាគីទីពីរក្នុងការទទួលបានដី ៥៥

៦. ការកាន់កាប់បច្ចុប្បន្នលើដីមានទំនាស់ ៥៩
៧. វិវាទដីធ្លីដែលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ច ៦០
៨. វិវាទដីធ្លីដែលមានផលប៉ះពាល់លើជនជាតិដើមភាគតិច ៦៣

៩. ការផ្ញើរទឹកឆ្លងដោយបង្ខំ ៦៤
១០. ឧបសម្ព័ន្ធ ៦៧
១១. សេចក្តីបន្ថែម ៦៩

អក្សរកាត់

ADHOC	សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា
CDC	ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
CEPA	សមាគមថែរក្សាបរិស្ថាន និង វប្បធម៌
CF	សហគមន៍ព្រៃឈើ
CLEC	មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
CNRO	អង្គការស្រាវជ្រាវជាតិកម្ពុជា
EIA	ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
ELC	សម្បទានដីសេដ្ឋកិច្ច
FA	រដ្ឋបាលព្រៃឈើ
GIS	ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
GIZ	សហគ្រាសសហព័ន្ធអាឡឺម៉ង់សម្រាប់សម្រាប់សហប្រត្តិការអន្តរជាតិ (GIZ) BmbH
Ha	ហិកតា
HH	គ្រួសារ
IMR	សិទ្ធិរបស់ជនជាតិដើមភាគតិច
IP	ជនជាតិដើមភាគតិច
KKKHRDA	សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ខ្មែរកម្ពុជា
LC	សម្បទានដី
LD	វិវាទដីធ្លី
LICADHO	សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ
MAFF	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
MoE	ក្រសួងបរិស្ថាន
NALDR	អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
NGOF	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
RAC	មជ្ឈមណ្ឌលស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង

RFA	វិទ្យុអាស៊ីសេរី
RGC	រាជរដ្ឋាភិបាលកម្ពុជា
SLC	សម្បទានដីសង្គមកិច្ច
SLR	ការចុះបញ្ជីដីធ្លីជាប្រព័ន្ធ
Vigilance	អង្គការឃ្លាំមើលសិទ្ធមនុស្សកម្ពុជា

និយមន័យនៃបច្ចេកសព្ទ

សម្រាប់គោលបំណងនៃរបាយការណ៍នេះ បច្ចេកសព្ទខាងក្រោម ត្រូវបានប្រើសំរាប់តែរបាយការណ៍នេះប៉ុណ្ណោះ ដូច្នេះអ្នកប្រើប្រាស់គប្បីប្រយ័ត្នប្រយែងក្នុងការប្រើបច្ចេកសព្ទទាំងនេះក្នុងស្ថានភាពដទៃទៀត។

ការបោះបង់ពាក្យបណ្តឹង: សំដៅលើករណីទាំងឡាយ ដែលបណ្តឹងទាមទារដីត្រូវបានបោះបង់ចោល ឬ រំលត់ដោយភាគីដើមបណ្តឹង។

ដីកសិកម្ម: ដីដែលមានលក្ខណៈសមស្របសម្រាប់ផលិតកម្មកសិកម្ម រួមមានដំណាំ និង បសុសត្វ (កន្លែងចិញ្ចឹមសត្វ)។

ការផ្លាស់ទីកន្លែងដោយបង្ខំ: ការបង្ខំប្រជាជនឲ្យចាកចេញពីដីដែលពួកគេរស់នៅ ឬដែលជាកន្លែងដែលពួកគេធ្វើសកម្មភាពកសិកម្ម ដែលផ្ទុយនឹងឆន្ទៈរបស់ពួកគេ។

វិវាទដីធ្លី: ការមិនឯកភាពរវាងគូរភាគីចាប់ពីពីរឡើង ទាក់ទិននឹងសិទ្ធិក្នុងការកាន់កាប់ ការគ្រប់គ្រង អាស្រ័យផល ឬ ការប្រើប្រាស់ដីជាក់លាក់លើផ្ទៃកណាមួយនៃក្បាលដី។ វិវាទដីធ្លី អាចពាក់ព័ន្ធលើដីទាំងមូល ឬ ដីមួយចំណែក និងអាចទាក់ទិនទៅនឹងព្រំប្រទល់ក្បាលដីដែលជាប់គ្នា។

ដីប្រើប្រាស់ច្រើនយ៉ាង: សំដៅលើដីទំនាស់ ដែលត្រូវបានប្រើសំរាប់គោលបំណងច្រើនយ៉ាង រួមមាន ដីដាំបន្លែនិងដំណាំ ដីស្រែនិងចំការ ព្រមទាំងដីលំនៅឋាន។ល។

អ្នកកាន់កាប់ដីដើម: សំដៅលើបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ ដែលបានប្រើ ឬបានកាន់កាប់ដី មុនពេលទំនាស់កើតឡើង។

ភាគីវិវាទ: សំដៅលើបុគ្គលដែលព្យាយាមទាមទារដីរបស់អ្នកកាន់កាប់ដីដើ

ម។

ករណីស្មៀមស្មាត់: សំដៅលើករណីដែលត្រូវបានដាក់ជូនអាជ្ញាធរមានសមត្ថកិច្ច ប៉ុន្តែក្នុងឆ្នាំកន្លងទៅ មិនមានវឌ្ឍនភាពអ្វីគួរឲ្យកត់សម្គាល់ឆ្ពោះទៅកាន់ដំណោះស្រាយ។

បណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN): គឺជាបណ្តាញអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើបញ្ហាសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាននៅកម្ពុជា ដែលសម្របសម្រួលដោយវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF)។ បណ្តាញនេះ រួមមាន៖

១) គណៈកម្មាធិការដឹកនាំ មានសមាសភាពជានាយកនៃបណ្តាអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានជ្រើសរើស។

២) គណៈកម្មាធិការថ្នាក់ជាតិនៃបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) មានសមាសភាពជានាយកកម្មវិធី ឬនាយកគម្រោងនៃអង្គការមិនមែនរដ្ឋាភិបាលជាសមាជិកដែលមានទីស្នាក់ការនៅរាជធានីភ្នំពេញ និង

៣) សមាជិកថ្នាក់ខេត្តនៃបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន (LAHRiN) រួមមានបណ្តាអង្គការមិនមែនរដ្ឋាភិបាលដែលមាន ទីស្នាក់ការនៅតាមខេត្តនានា និងធ្វើការលើបញ្ហាសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន។

១. សេចក្តីផ្តើម

វិវាទដីធ្លីនៅកម្ពុជា ត្រូវបានគេមើលឃើញជាទូទៅថាជាបញ្ហាមួយក្នុងចំណោមបញ្ហាប្រឈមដ៏ធំបំផុត ដែលប្រជាពលរដ្ឋកម្ពុជាកំពុងប្រឈមមុខ។ នៅក្នុងករណីធ្ងន់ធ្ងរ វិវាទដីធ្លីអាចឈានទៅដល់ការបាត់បង់ដីធ្លី និងការទទួលបានន្យវធនធានដែលមិនស្របទៅនឹងគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ កម្រិត និងការកើតមានវិវាទដីធ្លីនៅកម្ពុជា បង្កើតឲ្យមានកង្វល់ក្នុងចំណោមសហគមន៍ជាតិ និងអន្តរជាតិ។

តាមរយៈកំណត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យ របស់អេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បង្ហាញថា ករណីវិវាទដីធ្លីមួយចំនួន បានអូសបន្លាយជាច្រើនឆ្នាំ ហើយប្រការនេះ បានធ្វើឲ្យស្ថានភាពរស់នៅនិងជីវភាពរបស់ប្រជាជនរងផលប៉ះពាល់ធ្លាក់ចុះ។ កំណត់ត្រាទាំងនេះ បង្ហាញថា មានកត្តាជាច្រើនដែលបង្កឲ្យមានវិវាទដីធ្លី រួមមាន គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ទីក្រុងនិងជនបទ សម្បទានដីសេដ្ឋកិច្ច សម្បទានផ្សេងៗទៀត ដែលប្រតិបត្តិដោយស្ថាប័នជាតិ ការតាំងទីលំនៅលើដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ និងក្រុមហ៊ុនអន្តរជាតិ និងការរំលោភយកដីពីសំណាក់បុគ្គលជាដើម។

តាមច្បាប់តម្រូវឲ្យមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននិងសង្គម (SEIA) សម្រាប់គម្រោងអភិវឌ្ឍន៍ទាំងឡាយ។ ប៉ុន្តែជាញឹកញាប់គម្រោងទាំងនោះមិនបានធ្វើការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននិងសង្គមទេ ឬនៅពេលគម្រោងធ្វើការវាយតំលៃ គឺធ្វើទាបជាងស្តង់ដាដែលបានកំណត់ ដោយផ្តល់ឱកាសតិចតួចសំរាប់ការចូលរួមជាសាធារណៈ ដែលនាំឲ្យមិនមានការអនុវត្តច្បាប់ ដើម្បីការពារសិទ្ធិរបស់សហគមន៍មូលដ្ឋាន និងជំរុញឲ្យមានវិវាទដីធ្លីកាន់តែធ្ងន់ធ្ងរ មិនស្របទៅនឹងគោលដៅអភិវឌ្ឍន៍ជាតិ។

"ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជា" របស់ផេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានបង្កើតនិងចងក្រង តាំងពីឆ្នាំ២០០៧ មកម្ល៉េះ។ តាមរយៈស្ថិតិទាំងនោះ យើងឃើញថា វិវាទដីធ្លី បានកើនឡើងខ្ពស់បំផុតក្នុងឆ្នាំ២០០៨ ស្របពេលដែលតម្លៃដីនៅកម្ពុជាបានកើនឡើងយ៉ាងខ្លាំង។ នៅឆ្នាំបន្ទាប់ ចំនួនវិវាទដីធ្លី បានធ្លាក់ចុះបន្តិច ប៉ុន្តែក្នុងឆ្នាំ២០១០ ២០១១ និង ២០១២ ចំនួនវិវាទដីធ្លី បានចាប់ផ្តើមកើនឡើងម្តងទៀត។ ករណីវិវាទថ្មីៗក្នុងឆ្នាំ២០១៣ និងឆ្នាំ២០១៤ បានធ្លាក់ចុះម្តងទៀត បើធៀបទៅនឹងកំណត់ត្រានៅមុនឆ្នាំ២០១២។

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តមួយចំនួន ទាក់ទិននឹងដីធ្លីនិងធនធានធម្មជាតិ ដែលសំដៅដល់ការអនុវត្តនីតិវិធីទាំងឡាយ ពាក់ព័ន្ធនឹងរដ្ឋបាលនិងការគ្រប់គ្រងដីធ្លី រួមទាំង ការទប់ស្កាត់ទំនាស់ដីធ្លី និងដំណោះស្រាយវិវាទដីធ្លី។[1] បទបញ្ជា ០១ បានរៀបចំជាយន្តការដើម្បីផ្អាកជាបណ្តោះអាសន្នលើការផ្តល់សម្បទានដីសេដ្ឋកិច្ច អនុវត្តគោលនយោបាយស្បែកខ្លា ចំពោះប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច/សម្បទានដីនានា ការលុបចោលសម្បទានដីសេដ្ឋកិច្ច/សម្បទានដី ដែលមិនបានអនុវត្តតាមផែនការវិនិយោគរបស់ក្រុមហ៊ុន ដូចដែលបានកំណត់ក្នុងកិច្ចសន្យាវិនិយោគ។ យន្តការនេះ រំពឹងថានឹងអាចដោះស្រាយបញ្ហាវិវាទដីធ្លីបានកាន់តែប្រសើរ។ ប្រកាសអន្តរក្រសួងស្តីពីការពង្រឹងការគ្រប់គ្រងក្រុម

---

[1] ឧទាហរណ៍: ច្បាប់ភូមិបាលដែលត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១, សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលនយោបាយដីធ្លី (ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៩), ច្បាប់ស្តីពីអស្សាមិករណ៍ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០, សារាចរលេខ ០៣ ស្តីពីដំណោះស្រាយសំណង់បណ្តោះអាសន្ន ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១០, គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ឆ្នាំ ២០០៩, អនុក្រឹត្យលេខ ៨៣ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីសម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (L&R/L&P/២០០៩/Khm) (Ogs, ឆ្នាំ ២០០៩, លេខ ៥៣ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៩) និង ប្រកាសអន្តរក្រសួងស្តីពីវិធានការបណ្តោះអាសន្នការពារដីរបស់ជនជាតិដើមភាគតិច ដែលត្រូវបានស្នើសុំប័ណ្ណកម្មសិទ្ធិសមូហភាព ខណៈពេលរង់ចាំការផ្តល់ប័ណ្ណកម្មសិទ្ធិយោងតាមនីតិវិធីដែលត្រូវបញ្ចប់នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១។

ហ៊ុនសម្បទានដីសេដ្ឋកិច្ច ដែលចុះសហត្ថលេខាដោយ ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម និង ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤ ត្រូវបានចាត់ទុកថាជាយន្តការដើម្បីកាត់បន្ថយវិវាទដីធ្លីរបស់រដ្ឋាភិបាលក្នុងអណាត្តិទីប្រាំ។

ទោះជាយ៉ាងណាក៏ដោយ គេនៅមិនទាន់ដឹងច្បាស់ទេថាតើគោលនយោបាយ និងក្របខ័ណ្ឌថ្មីៗទាំងនោះ អាចអនុវត្តជោគជ័យកំរិតណា ពាក់ព័ន្ធទៅនឹងដំណោះស្រាយវិវាទដីធ្លី។ វិវាទដីធ្លីនៅកម្ពុជា នៅតែត្រូវបានរាយការណ៍ជាច្រើន ទាំងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិនិងអន្តរជាតិ។ ទិន្នន័យដែលបង្ហាញនៅក្នុងរបាយការណ៍នេះ អាចខុសពីទិន្នន័យដែលបានផ្សព្វផ្សាយដោយអង្គការដទៃៗទៀត ដោយសារការប្រើប្រាស់វិធីសាស្ត្រខុសៗគ្នានៃការប្រមូលព័ត៌មាន។ របាយការណ៍នេះ សំដៅតាមដានមើលនូវនិន្នាការនៅក្នុងការកើតឡើង និងមូលហេតុនៃវិវាទដីធ្លីដែលប្រមូលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងផ្តល់ភស្តុតាងជាឯកសារ សំរាប់ភាគីពាក់ព័ន្ធនានា ដែលចង់ស្វែងយល់ពីបញ្ហាដ៏សំខាន់នេះ

២. គោលបំណងនៃរបាយការណ៍

របាយការណ៍នេះ មានគោលបំណងផ្តល់នូវភស្តុតាងជាឯកសារនៃវិវាទដីធ្លីដែលកើតមានតាមបណ្តាឆ្នាំកន្លងមក រហូតដល់ឆ្នាំ២០១៥។ ទិន្នន័យទាំងនេះ បានប្រមូលពីអត្ថបទនានា ស្តីពីវិវាទដីធ្លីតាមរយៈសារព័ត៌មានបោះពុម្ពផ្សាយក្នុងស្រុក កិច្ចប្រជុំជាមួយសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) និងតាមរយៈការប្រមូលទិន្នន័យនៅមូលដ្ឋាន។ របាយការណ៍នេះ មានបំណងលើកកម្ពស់ការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្នទាក់ទិននឹងវិវាទដីធ្លី និងបំពេញមុខងារជាធនធានមួយសំរាប់ភាគីពាក់ព័ន្ធផ្សេងៗទៀត ដែលធ្វើការលើបញ្ហាដីធ្លី រួមមាន មន្ត្រីរាជរដ្ឋាភិបាល ម្ចាស់ជំនួយ សមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) អង្គការ

សង្គមស៊ីវិលជាតិនិងអន្តរជាតិ និងអ្នកសិក្សាស្រាវជ្រាវនានា។ របាយការណ៍នេះ ក៏អាចនឹងប្រើប្រាស់ជាឯកសារ ក្នុងការតស៊ូមតិដើម្បីលើកស្ទួយសុវត្ថិភាពកាន់កាប់ដីសម្រាប់ប្រជាជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជាផងដែរ។

លើសពីនេះទៅទៀត ខ្លឹមសារនៃរបាយការណ៍នេះ ក៏នឹងមានប្រយោជន៍ចំពោះភាគីពាក់ព័ន្ធ និងរាជរដ្ឋាភិបាលដែលកំពុងធ្វើការដើម្បីស្វែងរកដំណោះស្រាយ ចំពោះស្ថានភាពដីធ្លីបច្ចុប្បន្ននៃប្រទេសកម្ពុជា។ ផេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អាចដឹងថាលទ្ធផលនៃរបាយការណ៍នេះ អាចនឹងត្រូវបដិសេដក្តី ក៏យើងនៅតែសង្ឃឹមថា លទ្ធផលនៃការវិភាគវិវាទដីធ្លីនេះ នឹងចូលរួមចំណែកដល់ការអនុវត្តគោលនយោបាយនិងសកម្មភាពនានា ដែលនឹងនាំទៅដល់ដំណោះស្រាយចំពោះវិវាទដីធ្លីនៅកម្ពុជា។

៣. យន្តការដោះស្រាយវិវាទ

នៅក្នុងបរិបទនៃវិវាទដីធ្លី ការសំខាន់គឺត្រូវបែងចែករវាងវិវាទលើដី "គ្មានប័ណ្ណកម្មសិទ្ធិ" ពោលគឺដីដែលពុំមានការចេញប័ណ្ណកម្មសិទ្ធិផ្លូវការ និង វិវាទលើដី "មានប័ណ្ណកម្មសិទ្ធិ"។ យន្តការនៃការដោះស្រាយវិវាទដីធ្លី មានផ្សេងគ្នា និងអាស្រ័យទៅលើប្រភេទនៃវិវាទនិមួយៗ។ នៅកម្ពុជា មានយន្តការចំនួនប្រាំ ក្នុងការដោះស្រាយវិវាទដីធ្លីផ្លូវការ។ យន្តការដោះស្រាយវិវាទទាំងនេះ រួមមាន៖

- ក្រុមប្រឹក្សាឃុំ/សង្កាត់
- គណៈកម្មការសុរិយោដី
- គណៈកម្មការរដ្ឋបាល
- អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- តុលាការ

ក្រុមប្រឹក្សាឃុំ/សង្កាត់៖ មានភារៈកិច្ច "ផ្សះផ្សារនូវគំនិតដែលផ្ទុយ" រវាងប្រជាពលរដ្ឋក្នុងឃុំ ប៉ុន្តែមិនមានអំណាចធ្វើសេចក្តីសម្រេចឡើយ។[2] បើទោះបីជាមិនមាននីតិវិធីដោះស្រាយវិវាទដីធ្លីផ្លូវការសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ក៏ដោយ គេនៅតែឃើញមានករណីបណ្តឹងភាគច្រើន បានដាក់ចូលមកក្រុមប្រឹក្សាឃុំ/សង្កាត់ មុនពេលករណីទាំងនោះដាក់ទៅថ្នាក់លើ។[3] (សូមមើលតារាង ៥.៤.១)

គណៈកម្មការសុរិយោដី៖ មានយុត្តាធិការចំពោះវិវាទលើដីគ្មានប័ណ្ណកម្មសិទ្ធិ (*អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ មាត្រា៦*)។ គណៈកម្មការសុរិយោដី មាននៅកម្រិតស្រុក/ខណ្ឌ ដែលហៅថា "គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ(DKCC)" បន្ទាប់មកនៅកម្រិតខេត្ត/ក្រុង ហៅថា "គណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង(PMCC)" និងនៅថ្នាក់ជាតិ ហៅថា "គណៈកម្មការសុរិយោដីថ្នាក់ជាតិ(NCC)"។ ក្នុងករណីវិវាទដែលមិនអាចឈានដល់ដំណោះស្រាយប្រកបដោយសមធម៌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទ ជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង យោងតាមមូលហេតុ ដូចខាងក្រោម[4] ៖

(១) បុគ្គលម្នាក់ទាមទារកាន់កាប់ក្បាលដីមួយចំនួន ដែលដីទាំងនោះត្រូវបានទាមទារដោយអ្នកកាន់កាប់ដីដទៃទៀតដែរ។

(២) ភាគីមួយនៃភាគីទំនាស់ គឺជាអាជ្ញាធរថ្នាក់ខ្ពស់។

(៣) មានទំនាស់ផលប្រយោជន៍ជាមួយប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ។

---

[4] *យន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីទី ២ នៃអង្គការGIZ, ខែ សីហា ឆ្នាំ ២០១៤ បទបង្ហាញក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកដីធ្លីជាមួយដៃគូអភិវឌ្ឍន៍, ខែ សីហា ឆ្នាំ ២០១*

(៥) វិវាទពាក់ព័ន្ធដីសាធារណៈរបស់រដ្ឋ។[5]

ជាទូទៅ ករណីវិវាទនិមួយៗនឹងត្រូវឆ្លងកាត់នីតិវិធីជាច្រើន ដូចជា ការដាក់ពាក្យបណ្តឹង ការស៊ើបអង្កេត កិច្ចប្រជុំរដ្ឋបាល ការផ្សះផ្សារ និងការចុះបញ្ជីដី។ បន្ទាប់ពីមានកិច្ចប្រឹងប្រែងផ្សះផ្សារវិវាទដីធ្លី បីដងរួចមក [6] គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ ដែលជាគណៈកម្មការថ្នាក់ក្រោម មិនមានអំណាចធ្វើសេចក្តីសម្រេចលើវិវាទណាមួយឡើយ គឺអាស្រ័យទៅសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

គណៈកម្មការរដ្ឋបាល(AC) គណៈកម្មការនេះមិនមែនជាយន្តការដោះស្រាយវិវាទ អចិន្ត្រៃយ៍ទេ។ គណៈកម្មការរដ្ឋបាល មានវត្តមានជាលក្ខណៈបណ្តោះអាសន្ន ក្នុងអំឡុងពេលដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ គណៈកម្មការរដ្ឋបាល មានភារកិច្ចផ្សះផ្សារវិវាទ លើក្បាលដីនៅមិនទាន់មានប័ណ្ណកម្មសិទ្ធិ ទោះបីជាការទាមទារដោយបុគ្គល ក្រុមហ៊ុន ឬទាមទារដោយរដ្ឋ។ ករណីវិវាទដែលមិនអាចផ្សះផ្សារបាន ត្រូវបញ្ជូនទៅកាន់គណៈកម្មការសុរិយោដីថ្នាក់ជាតិ[7]។

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(NALDR) មានយុត្តាធិការលើករណីទាំងឡាយណាដែល "ហួសពីយុត្តាធិការ" របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធវិវាទដីធ្លី[8]។ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ត្រូវបានដឹកនាំដោយឧបនាយករដ្ឋមន្ត្រីមួយរូប និងមានក្រសួងអាជ្ញាធរចំនួន២៦ ជាសមាជិក។ សមាជិក១០រូប ផ្សេងទៀតបំពេញមុខងារជាអគ្គលេខាធិការដ្ឋាន ដែលដឹកនាំដោយ

---

6 *(មាត្រា ២៩, លេខ ១១២ ដនស/ប្រក, ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២, ប្រកាសស្តីពីគោលការណ៍ណែនាំ និង នីតិវិធីនៃគណៈកម្មការសុរិយោដី, សូមមើលយន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីទី ២ នៃអង្គការ GIZ, ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកដីធ្លីជាមួយដៃគូអភិវឌ្ឍន៍, ខែ សីហា ឆ្នាំ ២០១៤)*

7 *ដូចយោងខាងលើ*

8 *មាត្រា ៣, រាជក្រឹត្យ លេខ រស/រតក/០២០៦/៦៩៧*

គណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។

តុលាការ មានអាណត្តិដោះស្រាយវិវាទលើដីមានប័ណ្ណកម្មសិទ្ធិ។ អំណាចរបស់តុលាការមានបីកម្រិត ពោលគឺសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ប្រជាពលរដ្ឋក្រីក្រពុំមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធតុលាការ ក្នុងការដោះស្រាយវិវាទនោះទេ ដោយសារថ្លៃសេវាខ្ពស់ពេក។

តារាងខាងក្រោមបង្ហាញហានានុក្រមនៃយន្តការដោះស្រាយវិវាទ៖



ប្រភព: យន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីទី ២ នៃអង្គការ GIZ, ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកដីធ្លីជាមួយដៃគូអភិវឌ្ឍន៍, ខែ សីហា ឆ្នាំ ២០១៤។

៤. វិធីសាស្ត្រ

៤.១ លក្ខណៈវិនិច្ឆ័យសំរាប់កំណត់ករណីទំនាស់ដីធ្លី

របាយការណ៍នេះ វិភាគរាល់វិវាទដីធ្លីដែលបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក និងព័ត៌មានដែលប្រមូលបានពីសមាជិកបណ្តាញសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។ ដោយឡែកវិវាទដីធ្លីដែលបានកើតឡើង ប៉ុន្តែមិនមានចុះផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក ហើយសមាជិកបណ្តាញញសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋានមិនបានដឹង គឺមិនមាននៅក្នុងការវិភាគនេះទេ។ វិវាទដីធ្លីដែលបានផ្សព្វផ្សាយនៅប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក អាចកើតឡើងលើដីមានប័ណ្ណកម្មសិទ្ធិ ឬដីគ្មានប័ណ្ណកម្មសិទ្ធិ។

ស្ថិតិដែលបង្ហាញនៅក្នុងរបាយការណ៍នេះ អាចខុសពីប្រភពផ្សេងៗទៀត ដោយសារភាពខុសគ្នានៅក្នុងវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យនៃការប្រមូល និងការផ្ទៀងផ្ទាត់ទិន្នន័យ។ ផ្នែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង(RAC) ប្រើលក្ខណៈវិនិច្ឆ័យខាងក្រោម ដើម្បីកំណត់ករណីវិវាទដីធ្លី៖

- ករណីវិវាទដីធ្លីដែលពាក់ព័ន្ធចាប់ពី ៥គ្រួសារឡើង
- ករណីវិវាទដីធ្លីដែលនៅមិនទាន់ត្រូវបានដោះស្រាយ ឬ ដែលដោះស្រាយបានមួយផ្នែក និង
- ករណីវិវាទដីធ្លីដែលបានដោះស្រាយមុនឆ្នាំ២០១៥ ត្រូវដកចេញពីការវិភាគនេះ។ ប៉ុន្តែករណីដែលដោះស្រាយចប់ក្នុងឆ្នាំ២០១៥ ត្រូវដាក់បញ្ចូលក្នុងការវិភាគនេះ។

៤.២ ការប្រមូលទិន្នន័យ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីវិវាទដីធ្លី

ប្រព័ន្ធប្រមូលព័ត៌មាន និងការធ្វើបច្ចុប្បន្នភាពទិន្នន័យរបស់ផ្នែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង (RAC) មានដូចខាងក្រោម៖

- ការប្រមូលព័ត៌មានប្រចាំថ្ងៃស្តីពីករណីវិវាទដីធ្លី ធ្វើតាមរយៈការតាមដានមើលប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក (រួមមានកាសែតភ្នំពេញប៉ុស្ត វិទ្យុអាស៊ីសេរី វិទ្យុបារាំងអន្តរជាតិ កាសែតខេមបូឌាដេលី កាសែតកោះសន្តិភាព និងកាសែតរស្មីកម្ពុជា)។
- ដោយផ្អែកលើព័ត៌មានប្រមូលបាន ករណីវិវាទដីធ្លីនិមួយៗ ត្រូវឆ្លងកាត់កិច្ចដំណើរការផ្ទៀងផ្ទាត់មួយ ដើម្បីជៀសវាងការដាក់បញ្ចូលត្រួតគ្នាទៅក្នុងប្រព័ន្ធទិន្នន័យ ជាមួយសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន (LAHRiN) ថ្នាក់ខេត្ត តាមរយៈកិច្ចប្រជុំបណ្តាញរាល់ពីរខែម្តង។
- កិច្ចប្រជុំរាល់ពីរខែម្តង ក៏ជាឱកាសមួយដែលមិនត្រឹមតែដើម្បីធ្វើការផ្ទៀងផ្ទាត់ករណីវិវាទដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីប្រមូលព័ត៌មានស្តីពីវិវាទដីធ្លីទាំងឡាយ ដែលមិនបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន កំពុងកើតឡើងនៅក្នុងតំបន់គោលដៅរបស់សមាជិកបណ្តាញ។
- សមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) ថ្នាក់ខេត្ត ធ្វើការផ្ទៀងផ្ទាត់វិវាទដីធ្លីនៅមូលដ្ឋាន។ ដើម្បីប្រមូលទិន្នន័យពាក់ព័ន្ធ សមាជិកត្រូវបានតម្រូវប្រើទំរង់មួយ ដែលត្រូវបានរៀបចំដោយផ្នែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង។
- ផ្នែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង (RAC) ធ្វើយុទ្ធនាការប្រចាំឆ្នាំមួយ ដើម្បីធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់ទិន្នន័យវិវាទដីធ្លីទូទាំងប្រទេស។ យុទ្ធនាការនេះ ធ្វើឡើងដោយមានកិច្ចសហការជាមួយសមាជិកបណ្តាញ

សិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) ថ្នាក់ខេត្តនិមួយៗ ដែលធ្វើនៅក្នុងខែវិច្ឆិការៀងរាល់ឆ្នាំ។

- មន្ត្រីផ្នែកច្បាប់របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ចុះសិក្សាផ្ទាល់នៅតាមបណ្តាខេត្តមួយចំនួន ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានពិស្តារនូវរាល់ករណីវិវាទដីធ្លីទាំងឡាយណា ដែលសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) មិនអាចផ្ទៀងផ្ទាត់បាន។

៤.៣ ឧបករណ៍ប្រើប្រាស់ដៅក្នុងការវិភាគស្ថិតិ

ទិន្នន័យវិវាទដីធ្លីទាំងអស់ដែលប្រមូលបាន ត្រូវបានកត់ត្រាទុកក្នុងមូលដ្ឋានទិន្នន័យរបស់ផ្នែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង (RAC)។ កម្មវិធីកុំព្យូទ័រមួយចំនួន រួមមាន Microsoft Excel, Statistical Package for the Social Science (SPSS software) និងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographic Information System (GIS) ត្រូវបានប្រើប្រាស់សំរាប់វិភាគករណីទាំងនោះ ដោយផ្តល់នូវស្ថិតិរួមមួយអំពីវិវាទដីធ្លីនិងទីកន្លែងភូមិសាស្ត្រនៃវិវាទដីធ្លី។

៤.៤ ដែនកំណត់នៃការប្រមូលព័ត៌មាន

ការប្រមូលព័ត៌មានស្តីពីវិវាទដីធ្លី គឺពឹងផ្អែកភាគច្រើនលើការប្រមូលព័ត៌មានស្តីពីព្រឹត្តិការណ៍នៃវិវាទដីធ្លីចេញពីប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ប៉ុន្តែនៅមានករណីជាច្រើនទៀត ដែលមិនបានរាយការណ៍នៅក្នុងរបាយការណ៍នេះ។ ផ្នែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង(RAC) ព្យាយាមកាត់បន្ថយបញ្ហានេះ ដោយប្រមូលទិន្នន័យពីសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) ប៉ុន្តែសមាជិកទាំងនោះមិនមានធ្វើសកម្មភាពនៅគ្រប់តំបន់ទូទាំងប្រទេសទេ ដូចនេះវិវាទដីធ្លីមួយចំនួនអាចមើលមិនឃើញ។

ម្យ៉ាងវិញទៀត ការវិភាគនេះ មិនបានដាក់បញ្ចូលទិន្នន័យស្តីពីករណីទាំងឡាយដែលបាននិងកំពុងដំណើរការដោះស្រាយ ដោយគណៈកម្មការរដ្ឋបាលគណៈកម្មការសុរិយោដី ឬក្រុមប្រឹក្សាឃុំទេ។ លើកលែងតែករណីវិវាទដីធ្លី ដែលដោះស្រាយដោយស្ថាប័នទាំងនោះត្រូវបានរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក។

៥. លទ្ធផលនៃការវិភាគទិន្នន័យ

ទិន្នន័យនិងក្រាហ្វិកដែលបង្ហាញជូនក្នុងរបាយការណ៍នេះ គឺពឹងផ្អែកទៅលើមូលដ្ឋានទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ដែលបានរៀបចំនិងចងក្រងទុកតាំងពីឆ្នាំ២០០៧មក។

៥.១ ទិន្នន័យដីធ្លីគិតតាមឆ្នាំ

សរុបករណីវិវាទដីធ្លីថ្មីដែលកើតឡើងក្នុងឆ្នាំ២០១៥ មានចំនួន ២៣[9] ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់អ្នកស្រាវជ្រាវដូចបានកំណត់ខាងលើ។ ករណីវិវាទថ្មីក្នុងឆ្នាំ២០១៥នេះ មានចំនួនស្មើគ្នាទៅនឹងចំនួនករណីដែលបានកើតមាននៅក្នុងឆ្នាំ ២០១៤ ប៉ុន្តែទាបជាងបណ្តាករណីវិវាទថ្មីដែលកើតឡើងក្នុងឆ្នាំ២០១០ ចំនួន៣៩, ២០១១ ចំនួន៣៩, ២០១២ ចំនួន៤៦ និង២០១៣ ចំនួន២៨។ ការធ្លាក់ចុះនូវចំនួនវិវាទដីធ្លីកើតថ្មីនេះ អាចបណ្តាលមកពីប្រសិទ្ធភាពនៃការអនុវត្តយន្តការរបស់រដ្ឋាភិបាលនាពេលកន្លងមក។ ជាក់ស្តែងនៅខែឧសភា ឆ្នាំ២០១២ រដ្ឋាភិបាល បានចេញប្រកាសផ្អាកជាបណ្តោះអាសន្នក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី ហើយគណៈកម្ម

[9] សូមមើលឧបសម្ព័ន្ធទី ១។

ការអន្តរក្រសួង ក៏ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៤ ដើម្បីធ្វើការពិនិត្យឡើងវិញ ចំពោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនសម្បទាន។



រូបទី ១ ករណីវិវាទដីធ្លីដែលកើតថ្មីៗតាមណ្តាឆ្នាំនិមួយៗ

ករណីវិវាទដីធ្លីកើតមានថ្មីក្នុងឆ្នាំ២០១៥ទាំង២៣ មាននៅក្នុងខេត្តចំនួន១១ ដែលក្នុងនោះ ខេត្តស្វាយរៀង មានករណីវិវាទដីធ្លីកើតថ្មីខ្ពស់ជាងគេ ចំនួន៦ករណី បន្ទាប់មក ខេត្តបាត់ដំបង មានវិវាទដីធ្លីកើតថ្មីចំនួន៥ករណី ខេត្តកំពង់ធំ ក្រចេះ និង ស្ទឹងត្រែង មានវិវាទដីធ្លីកើតថ្មីចំនួន២ករណីរៀងៗខ្លួន។ ចំណែកឯខេត្តកំពង់ស្ពឺ កែប ព្រះវិហារ ព្រៃវែង សៀមរាប និងត្បូងឃ្មុំ មានករណីវិវាទដីធ្លីថ្មីចំនួន១រៀងៗខ្លួន។

ល.រ	ខេត្ត	ឆ្នាំនៃការកើតវិវាទ	#វិវាទ
១	បន្ទាយមានជ័យ	២០១៥	០
២	បាត់ដំបង	២០១៥	៥
៣	កំពង់ចាម	២០១៥	០
៤	កំពង់ឆ្នាំង	២០១៥	០
៥	កំពង់ស្ពឺ	២០១៥	១
៦	កំពង់ធំ	២០១៥	២
៧	កំពត	២០១៥	០
៨	កណ្តាល	២០១៥	០
៩	កោះកុង	២០១៥	០
១០	ក្រចេះ	២០១៥	២
១១	កែប	២០១៥	១
១២	មណ្ឌលគិរី	២០១៥	០
១៣	ឧត្តរមានជ័យ	២០១៥	០
១៤	ភ្នំពេញ	២០១៥	០
១៥	ព្រះវិហារ	២០១៥	១
១៦	ព្រៃវែង	២០១៥	១
១៧	ពោធិ៍សាត	២០១៥	០
១៨	ប៉ៃលិន	២០១៥	០
១៩	ព្រះសីហនុ	២០១៥	០
២០	រតនគិរី	២០១៥	០
២១	សៀមរាប	២០១៥	១
២២	ស្ទឹងត្រែង	២០១៥	២
២៣	ស្វាយរៀង	២០១៥	៦
២៤	តាកែវ	២០១៥	០
២៥	ត្បូងឃ្មុំ	២០១៥	១
សរុប			**២៣**

តារាងទី ១៖ ករណីវិវាទដីធ្លីដែលកើតថ្មីៗក្នុងឆ្នាំ២០១៥ នៅតាមបណ្តាខេត្ត

បន្ថែមពីចំនួនវិវាទទាំង២៣ករណី ដែលបានរកឃើញថ្មីនៅឆ្នាំ២០១៥ នៅមានករណីវិវាទដីធ្លី ចំនួន១៥ទៀត ដែលបានកើតឡើងមុនឆ្នាំ២០១៥ ហើយករណីទាំងនោះមិនទាន់បានរាយការណ៍នៅក្នុងបណ្តាឆ្នាំមុនៗឡើយ។ ករណីទាំងនោះ ក៏បានដាក់បញ្ចូលទៅក្នុងការវិភាគនេះសំរាប់ឆ្នាំ២០១៥នេះផងដែរ។ សរុបមក ករណីវិវាទដីធ្លីដែលផ្នែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង បានធ្វើការតាមដានចាប់តាំងពីឆ្នាំ ២០០៧មក មានចំនួន៣០៨ករណី។

នៅក្នុងចំណោមវិវាទដីធ្លីទាំង ៣០៨ករណីដែលបានបញ្ជាក់ជូនខាងលើ មានករណីវិវាទចំនួន២៨៥ករណី ពុំទាន់បានដោះស្រាយ និងកំពុងរងចាំដំណោះស្រាយសំរាប់គូរភាគីវិវាទ។



រូបទី ២: ករណីវិវាទតាមបណ្តាឆ្នាំនិមួយៗដែលបានធ្វើការផ្សៀងផ្ទាត់ឆ្នាំ២០១៥

៥.២ ទីតាំងនៃវិវាទ

នៅក្នុងករណីវិវាទដីធ្លីចំនួន ២៨៥ករណី ដែលពុំទាន់និងកំពុងរងចាំការដំណោះស្រាយ មានករណីវិវាទមួយចំនួនដោះស្រាយបានលទ្ធផលមួយផ្នែក ប៉ុន្តែវិវាទមិនទាន់បានបញ្ចប់។ ករណីមួយចំនួនទៀត ទើបតែចាប់នៅក្នុងដំណើការនៃការដំណោះស្រាយវិវាទជាមួយនឹងនីតិវិធីមិនច្បាស់លាស់ ហើយករណីមួយចំនួនទៀតនៅមានសភាព"ស្ងៀមស្ងាត់" ដែលមានន័យថា បណ្តឹងត្រូវបានដាក់ជូនស្ថាប័នមានសមត្ថកិច្ចនិងអាជ្ញាធររួចហើយ ប៉ុន្តែពុំមានចំណាត់ការដោះស្រាយនៅឡើយ។

វិវាទដីធ្លីទាំងនោះ កើតមាននៅទូរទាំង ២៤ខេត្ត និងរាជធានីភ្នំពេញ។ ៧២ ករណី កើតមាននៅក្នុងខេត្តចំនួន១៣ មានដូចជា កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត កណ្តាល កែប ក្រចេះ ឧត្តរមានជ័យ ប៉ៃលិន ព្រៃវែង ស្ទឹងត្រែង តាកែវ និងខេត្តត្បូងឃ្មុំ មានវិវាទចន្លោះពី ១ករណី ទៅដល់ ១០ករណី។ ១៦៦ករណី កើតមាននៅក្នុងខេត្តចំនួន១០ មានដូចជា កំពង់ស្ពឺ កោះកុង មណ្ឌលគីរី ព្រះវិហារ ព្រះសីហនុ ពោធិ៍សាត់ សៀមរាប និងខេត្តស្វាយរៀង មានវិវាទចន្លោះពី ១១ករណី ទៅដល់ ២០ករណី។ ចុងក្រោយ ៤៧ករណី កើតមាននៅរាជធានីភ្នំពេញ និងខេត្តរតនគីរី ដែលមានវិវាទធំជាង២០ករណី។

តាមការគូសបញ្ជាក់នៃរូបទី៣ខាងក្រោម បង្ហាញថាគិតត្រឹមឆ្នាំ២០១៥ ករណីវិវាទដីធ្លី កើតមានខ្ពស់ជាងគេគឺនៅរាជធានីភ្នំពេញ មានចំនួន ២៥ករណី ហើយខេត្តបន្ទាប់ទៀត គឺរតនគិរី បន្ទាយមានជ័យ និងបាត់ដំបង មានករណីវិវាទដីធ្លីចំនួន២២ ២០ និង២០។



រូបទី ៣: ចំនួននៃវិវាទដីធ្លី តាមបណ្តាខេត្តគិតត្រឹមឆ្នាំ២០១៥

៥.២.១ វិវាទដីធ្លីនៅរាជធានីភ្នំពេញ

គេឃើញមានវិវាទដីធ្លីកើតឡើងនៅគ្រប់ខណ្ឌទាំង១២នៃរាជធានីភ្នំពេញ។ វិវាទទាំងនោះ មានចំនួនសរុប ២៥ករណី ក្នុងនោះខណ្ឌដង្កោ កើតមានវិវាទដីធ្លីខ្ពស់ជាងគេចំនួន៦ករណីនៅក្នុងសង្កាត់ចំនួន៦ និងខណ្ឌឫស្សីកែវ កើតមានវិវាចំនួន៥ករណីនៅក្នុងសង្កាត់ចំនួន៥។ គួរកត់សំគាល់ផងដែរថា ២ករណីក្នុងចំណោមករណីទាំង៦នៃខណ្ឌដង្កោ ភាគីខាងចុងបណ្តឹង ជាក្រុមហ៊ុនសហការជាមួយក្រុមប៉ូលីស បានបង្ករការគំរាមហែងនិងប្រើអំពើហឹង្សដល់ភាគីដើមបណ្តឹងដែលជាសកម្មជនដីធ្លី។ ក្នុងនោះជនរងគ្រោះនៃវិវាទដីធ្លី ចំនួន ១០នាក់ ត្រូវបានប៉ូលីសចាប់ឃុំខ្លួន ហើយក្រោយមកពួកគាត់ត្រូវបានប៉ូលីសដោះលែងវិញ។ លើសពីនេះទៀតករណីវិវាទដីធ្លីមួយផ្សេងទៀតនៅក្នុងខណ្ឌឫស្សីកែវ ពាក់ព័ន្ធនឹងការអភិឌ្ឍន៍ផ្លូវរថភ្លើង មានប្រជាពលរដ្ឋរងផលប៉ះពាល់ ចំនួន ១៤៨គ្រួសារ រស់នៅតាមបណ្តោយផ្លូវរថភ្លើង (តំបន់ ICM 6) ត្រូវប្តូរទីតាំងឲ្យទៅរស់នៅក្នុងសង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ[10]។ ក្នុងករណីនេះ ប្រជាពលរដ្ឋមិនមានការពេញចិត្តឡើយ ចំពោះ

[10] មុនឆ្នាំ២០១២ ឃុំត្រពាំងក្រសាំងនេះស្ថិតនៅក្នុងខណ្ឌដង្កោ បន្ទាប់មកត្រូវបានកាត់ចូលទៅក្នុងខណ្ឌពោធិ៍សែន

សំណងដែលបានផ្តល់ជូនដោយភាគីក្រុមហ៊ុន។ ប្រជាពលរដ្ឋ នៅតែបន្តដាក់ពាក្យបណ្តឹងទៅកាន់អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីស្វែងរកការជួយអន្តរាគមន៍។ បច្ចុប្បន្ន ស្ថានភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋដែលផ្លាស់ទៅទីតាំងថ្មី កំពុងប្រឈមជាមួយបញ្ហាមួយចំនួន ដូចជា ក) ជំពាក់ប្រាក់ធនាគារ ដែលខ្វីសំរាប់ធ្វើការសាងសង់ផ្ទះនៅទីតាំងថ្មី។ ខ) គ្មានការងារ និងមុខរបរដើម្បីបង្កើនប្រាក់ចំណូលដោយសារនៅទីតាំងថ្មីឆ្ងាយពីទីផ្សារការងារ ផ្ទុយពីទីតាំងចាស់ពួកគាត់អាចធ្វើការជាកម្មករឆាងចក្រ និងលក់ដូរនៅផ្សារក្បែរផ្ទះ។ គ) កូនៗរបស់ពួកគាត់មិនអាចចូលសាលារៀនបានដោយសារតែឪពុកម្តាយ ពុំមានការងារធ្វើ និងគ្មានលទ្ធភាពផ្គត់ផ្គង់ការសិក្សារបស់កូន។ ឃ) ទីតាំងថ្មីមានការលិចទឹក ខ្វះអនាម័យ និងនៅឆ្ងាយពីសេវាសុខភាព។[11]

ខណ្ឌ/ស្រុក	សង្កាត់	ភូមិ	#វិវាទដីធ្លី
ច្បារអំពៅ	ព្រែកថ្មី	ចំពុះក្អែក	១
ជ្រោយចង្វារ	កោះដាច់	ចុងកោះ	១
ដង្កោ	ជើងឯក		២
	ព្រៃសរ		១
	ព្រែកកំពិស	ព្រែកកំពិស	១
	ព្រែកកំពិស	ដំណាក់សង្កែ	១
	ត្រពាំងក្រសាំង	ត្រពាំងអញ្ជាញ	១
ដូនពេញ	ស្រះចក		១
មានជ័យ	ចាក់អង្រែលើ	ព្រែកតានូ	១
	ស្នឹងមានជ័យ		២
	ចាក់អង្រែក្រោម		១

ជ័យ។

[11] ពត៌មាននេះទទួលបានពីតំណាងប្រជាពលរដ្ឋដែលរងគ្រោះតាមរយៈការទំនាក់ទំនងតាមទូរស័ព្ទ

ពោសែនជ័យ	ចោមចៅ	ព្រៃកំបុត	១
	ចោមចៅ	ថ្មគោល, ព្រៃពោរ, ត្រពាំងស្នោរ, គោចំបក, តាងួន	១
ព្រៃកញ្ជៅ	ពញ្ញាពន់	ធំត្បូង, ធំជើង	១
៧ កមរា	វាលវង្ស		១
ឬស្សីកែវ	គីឡូម៉ែត្រលេខប្រាំ	បឹងឈូក	២
	ទួលសង្កែ		១
	ភ្នំពេញថ្មី	ទំនប់	១
	ព្រៃកលាភ	កៀនឃ្លាំង	១
សែនសុខ	ភ្នំពេញ	រោងចក្រ	១
ទួលគោក	បឹងកក់ii	ភូមិ២៣	១
	បឹងកក់ii		១
សរុប			**២៥**

តារាងទី ២: ចំនួនវិវាទ តាមសង្កាត់ និង ខណ្ឌនៅរាជធានីភ្នំពេញ



ផែនទី ទី ១: វិវាទដីធ្លីនៅរាជធានីភ្នំពេញ គិតតាមសង្កាត់

៥.២.២ វិវាទដីធ្លីនៅខេត្តរតនគិរី

មានវិវាទដីធ្លី ចំនួន ២២ករណី កំពុងកើតមាននៅក្នុងខេត្តរតនគិរី ដែលជាខេត្តជាប់លំដាប់ថ្នាក់ទីពីរ បន្ទាប់ពីរាជធានីភ្នំពេញ។ វិវាទដីធ្លី ទាំង ២២ករណីនោះ បានបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនឯកជនមានឈ្មោះថា លី សុងីម ដែលជាក្រុមហ៊ុនឯកជនវិនិយោគលើដំណាំកៅស៊ូ លើផ្ទៃដី ៧០ ហិកតា។ ក្នុងនោះស្រុកអណ្តូងមាស កើតមានវិវាទដីធ្លីខ្ពស់ជាងគេ ដែលមានវិវាទដីធ្លី ចំនួន ៦ករណី នៅក្នុងឃុំចំនួន៣ និងប៉ះពាល់ដល់ជនជាតិដើមភាគតិច ចំនួន ១០៥៧គ្រួសារ។ លើសពីនេះទៅទៀត ករណីវិវាទដីធ្លី បានប៉ះពាល់ដល់ដីច្រើនប្រភេទរបស់ជនជាតិដើមភាគតិច មានដូចជា ដីចំការរំលងុំ ដីកប់ខ្មោច ដីអរក្ស និងដីព្រៃការពារ/

ដីព្រៃបំរុងទុកសំរាប់ការប្រមូលអនុផលព្រៃឈើ។ ទោះបីជាយ៉ាងណាក៏ដោយ ករណីវិវាទ ចំនួន៥ ដោះស្រាយបានលទ្ធផលមួយផ្នែក និងមួយករណីទៀត កំពុងស្ថិតក្នុងដំណើការដោះស្រាយ។

ចំណែកឯស្រុកបរកែវវិញ វិវាទដីធ្លីចំនួន៥ករណី កើតនៅក្នុងឃុំចំនួន២ មិនទាន់បានដោះស្រាយនៅឡើយទេ។ ក្នុងនោះករណីវិវាទដីធ្លីមួយ បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច[12] បានធ្វើឲ្យប៉ះពាល់ដល់ស្រុកចំនួន៣ រួមមាន ស្រុកបានលុងស្រុកអូរជុំ និងស្រុកបរកែវ។ ករណីវិវាទដីធ្លីមួយនេះ មានភាពស្មុគស្មាញដោយសារតែការផ្លាស់ប្តូរក្រុមហ៊ុនពីមួយទៅមួយ ខណៈដែលករណីវិវាទដីធ្លីនៅមិនទាន់បានដោះស្រាយនៅឡើយ។

ខណ្ឌ/ស្រុក	សង្កាត់/ឃុំ	ភូមិ	#វិវាទដីធ្លី
អណ្តូងមាស	ម៉ាលិក	កាហល	១
	ម៉ាលិក	ម៉ាលិក	១
	តាឡាវ	កាណាត	១
	តាឡាវ	កាក់	១
	តាឡាវ	កាក់	១
	ញ៉ាង	តាំងសៃ	១
បរកែវ	កិចុង	ប៉ាអរ	៤
	ឡាមីង	ស៊ូ	១
កូនមុំ	ត្រពាំង		១

[12] កាលពីមុនក្រុមហ៊ុនដែលបង្ករវិវាទគឺក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលមានឈ្មោះថា តាយសេង ប៉ុន្តែនៅក្នុងឆ្នាំ២០១៥ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយនេះបានលក់ទៅឲ្យក្រុមហ៊ុនចិនដែលមានឈ្មោះស្វីវ៉ាប់ប័រ ហើយប្រជាពលរដ្ឋក្នុងតំបន់ក៏បានឮដំណឹងថាក្រុមហ៊ុនមួយនេះនឹងបន្តលក់ទៅក្រុមហ៊ុនបារាំងទៀតបើទោះបីករណីវិវាទមិនទាន់បានដោះស្រាយក៏ដោយ។

	ក្រហម		
	ស្រែអង្រ្កង	ភូមិបី	១
លំជាត់	ប៉ាតាំង	ប៉ាតាំង	១
	សេដា	សមុត្រលើ	២
	ជ័យឧត្តម		១
អូរជុំ	អូរជុំ	តាំងកាមាល់	១
	ល្អក់	កាំ	១
អូរយ៉ាដាវ	ផេត	គង់យូ	១
	យ៉ាទង់		១
បានលុង/អូរជុំ/បរកែវ			១
សរុប			**២២**

តារាងទី ៣: ចំនួនវិវាទ គិតតាមឃុំ/សង្កាត់ និងស្រុកនៅខេត្តរតនគិរី



ផែនទីទី ២: វិវាទដីធ្លីនៅខេត្តរតនគិរី គិតតាមឃុំ

៥.៣ ករណីវិវាទដីធ្លីដែលបានដោះស្រាយ គិតតាមឆ្នាំ

ដូចដែលបានបង្ហាញនៅក្នុងដ្យាក្រាមខាងក្រោម (រូបទី៣) ក្នុងឆ្នាំ២០១៥ វិវាទដីធ្លីចំនួន ៣០៨ករណី បានធ្វើការតាមដាននិងផ្ទៀងផ្ទាត់នៅទូទាំងប្រទេស ហើយជាលទ្ធផលយើងឃើញថា មានករណីវិវាទដីធ្លីចំនួន ២៨៥ករណី កំពុងរងចាំដំណោះស្រាយ។ មានតែវិវាទចំនួន ២១ករណីប៉ុណ្ណោះ បានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១៥។ ចំនួននេះ បើធៀបនឹងករណីវិវាទដែលបានដោះស្រាយចប់ពេញលេញទាំងស្រុង តាមបណ្តាឆ្នាំមុនៗ មានចំនួនទាបជាងឆ្នាំ២០១៤ មាន៦១ករណី, ២០១៣ មាន៨១ករណី, ២០១២ មាន១០៨ករណី និង២០១១ មាន៤០ករណី។

គួរកត់សំគាល់ផងដែរថា ចំនួនករណីវិវាទដីធ្លីដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១៥ នេះទាបជាង៥ដង នៃករណីដែលបានដោះស្រាយចប់

ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១២ ជាឆ្នាំមុនការបោះឆ្នោតជាតិ។ ការធ្លាក់ចុះនៃចំនួនវិវាទដីធ្លីដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងនេះ ហាក់បានបង្ហាញថាយន្តការដែលបានកំណត់ដើម្បីដោះស្រាយវិវាទដីធ្លីកន្លងមកមិនទាន់មានប្រសិទ្ធភាពនៅឡើយ ឬមិនទាន់ឆ្លើយតបតាមតម្រូវការ។



រូបទី ៣: ករណីវិវាទដីធ្លីតាមបណ្តាឆ្នាំដែលត្រូវបានដោះស្រាយក្នុងឆ្នាំ ២០១៥

ករណីវិវាទដីធ្លីទាំង២១ករណី ដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងនៅក្នុងឆ្នាំ២០១៥ បានកើតឡើងនៅក្នុងឆ្នាំផ្សេងៗគ្នា ដូចដែលបានបង្ហាញក្នុងរូបភាពទី៤ (បន្ទាត់ពណ៌បៃតង)។ ក្នុងនោះមានចំនួន៤ករណី កើតក្នុងឆ្នាំ២០០៨ ៣ករណី កើតឆ្នាំ២០០៧ និង ៣ករណី កើតឆ្នាំ២០១០។

ចំណែកឯ២ករណីទៀត កើតឆ្នាំ១៩៩៩ ដែលបានចំណាយពេលអស់រយៈ ១៦ឆ្នាំ ទើបអាចដោះស្រាយចប់ពេញលេញទាំងស្រុងនៅក្នុងឆ្នាំ២០១៥។ ករណីមួយក្នុងចំណោមករណីទាំងពីរក្នុងឆ្នាំ១៩៩៩ កើតនៅក្នុងខេត្តត្បូងឃ្មុំ តាមបណ្តោយព្រំដែន

កម្ពុជា-វៀតណាម ជាវិវាទរវាងប្រជាពលរដ្ឋចំនួន ៧០០គ្រួសារ ជាមួយទាហាន[13] ដែលគំរាមកំហែងរំលោភយកដីប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋរងគ្រោះ បានដាក់ពាក្យបណ្តឹងជាច្រើនដងទៅកាន់អាជ្ញាធរ និងស្ថាប័នមានសមត្ថកិច្ច រួមមាន: អាជ្ញាធរស្រុក ខេត្ត និងខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដើម្បីសុំឲ្យមានដំណោះស្រាយ។ ក្រោយមកករណីវិវាទនេះ បានរដោះស្រាយតាមរយៈចំណារពីនាយករដ្ឋមន្ត្រីជូនទៅអាជ្ញាធរខេត្ត និងបានដោះស្រាយនៅក្នុងឆ្នាំ២០១៥ ដោយស្ថានភាពវិវាទ បានវិលត្រឡប់ដូចស្ថានភាពដើម និងអនុញ្ញាត្តិឲ្យប្រជាពលរដ្ឋរងគ្រោះប្រើប្រាស់ និងអាស្រ័យផលប៉ុន្តែមិនទាន់ចេញប័ណ្ណកម្មសិទ្ធឲ្យប្រជាពលរដ្ឋនៅឡើយទេ។ លើសពីនេះទៅទៀត ដីមួយផ្នែក ដែលជាដីតំបន់សនៃព្រំដែនកម្ពុជា-វៀតណាម គឺកំពុងតែរង់ចាំដំណោះស្រាយជាបន្តបន្ទាប់រហូតដល់ពេលដែលការបោះបង្គោលព្រំដែលរវាងកម្ពុជា-វៀតណាមចប់សព្វគ្រប់។

វិវាទដីធ្លី ចំនួន ៤ករណី ក្នុងចំណោមករណីវិវាទចំនួន២១ ដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១៥ ធ្លាប់មានការគំរាមកំហែង និងប្រើប្រាស់អំពើហឹង្សា ព្រមទាំងមានប្រជាពលរដ្ឋមួយចំនួនត្រូវឃុំខ្លួន។ ជាក់ស្តែង ករណីវិវាទដីធ្លីមួយដែលកើតមានក្នុងខេត្តបាត់ដំបង ស្រុកបវេល ឃុំខ្នាចរមាស ភូមិជ្រួយស្នារវាងប្រជាពលរដ្ឋ១៦គ្រួសារ ជាមួយនិងលោក អៀង អឿន ដែលមានប័ណ្ណដីធ្លីចំនួន ២២ប័ណ្ណ លើផ្ទៃដីវិវាទចំនួន ១០១ហិកតា មានប្រជាពលរដ្ឋចំនួន ៧នាក់ ត្រូវបានចាប់ឃុំខ្លួនក្នុងឆ្នាំ២០១២[14]។

[13] ករណីលេខ២៦៦១ ក្នុងទិន្នន័យមូលដ្ឋានរបស់ NGOF

[14] ករណីលេខ ២០៧៦



រូបទី ៤:ចំនួនករណីវិវាទដីធ្លីដែលត្រូវបានដោះស្រាយ គិតតាមឆ្នាំ

ទោះជាយ៉ាងណាក៏ដោយ វិវាទដីធ្លីកើតឡើងមុនឆ្នាំ២០០០ ចំនួន ១៥ករណី នៅមិនទាន់បានចាប់ផ្តើមដោះស្រាយ និងមិនទាន់បានដោះស្រាយចប់ពេញលេញទាំងស្រុងនៅឡើយទេ ក្នុងឆ្នាំ២០១៥នេះ។ ដូចដែលបានបង្ហាញលើក្រាហ្វិចក្នុងរូបភាពទី៤ ករណីដែលបានដោះស្រាយចប់ពេញលេញទាំងស្រុង(បន្ទាត់ពណ៌បៃតង) នៅមានចំនួនតិចតួចនៅឡើយ បើប្រៀបធៀបទៅនឹងករណីដែលកំពុងកើតមានក្នុងឆ្នាំនិមួយៗ (បន្ទាត់ពណ៌ក្រហម)។

៥.៤ ដំណោះស្រាយករណីវិវាទដីធ្លី

៥.៤.១ ស្ថាប័នទទួលពាក្យបណ្តឹង

ភាគីវិវាទ ទាំងអ្នកកាន់កាប់ដីដើម និងភាគីទីពីរ បានដាក់ពាក្យបណ្តឹងរបស់ពួកគេទៅស្ថាប័នរដ្ឋដែលពាក់ព័ន្ធ និងស្ថាប័នតុលាការ។ ក្នុងចំណោមវិវាទ ៣០៨ ករណី មានបណ្តឹងសរុបចំនួន ៨៨១បណ្តឹង ដែលកត់ត្រាក្នុងមូលដ្ឋានទិន្នន័យរបស់

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។ ពាក្យបណ្តឹងមួយចំនួន បានដាក់ជូនស្ថាប័នរាជរដ្ឋាភិបាល រួមមាន អាជ្ញាធរមូលដ្ឋាន ឃុំ/សង្កាត់ ស្រុក/ខណ្ឌ សាលាខេត្ត គណៈកម្មការសុរិយោដីទាំងបីថ្នាក់ (ស្រុក/ខ័ណ្ឌ ខេត្ត/ក្រុង ជាតិ) ស្ថាប័នថ្នាក់ជាតិ (រាយនាមនៅក្នុងកថាខណ្ឌបន្ទាប់នេះ) និង តុលាការ។

ក្នុងតារាងទី៤ខាងក្រោម បង្ហាញថា អាជ្ញាធរមូលដ្ឋាន ទទួលបានពាក្យបណ្តឹងច្រើនជាងគេ មានចំនួន ១៩៨បណ្តឹង ឬស្មើរនឹង ៦៤ភាគរយ នៃករណីវិវាទសរុបទាំង ៣០៨ ករណី។ ក្នុងនោះមានវិវាទដីធ្លី ចំនួន៣ករណីក្នុងចំណោមវិវាទចំនួន ១៨ករណី ឬ ១៧ភាគរយនៃវិវាទក្នុងខេត្តស្វាយរៀង បានដាក់ពាក្យបណ្តឹងទៅកាន់អាជ្ញាធរខេត្ត ដោយមិនឆ្លងកាត់អាជ្ញាធរមូលដ្ឋាន (ឃុំ/សង្កាត់ និងស្រុក) ហើយករណី៨៣%ទៀត បានដាក់ទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក និងទៅស្ថាប័នដែលមានកម្រិតខ្ពស់ជាង ដូចជា ក្រសួងមាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋសភា ក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច។ ប៉ុន្តែករណីទាំងនោះ មិនទាន់បានដោះស្រាយចប់នៅឡើយ។ នេះមិនមែនជាការចម្លែកទេ ដែលករណីពាក្យបណ្តឹងមួយចំនួន ដាក់ទៅស្ថាប័នដែលមានកម្រិតខ្ពស់ ហើយមិនបានដាក់ទៅអាជ្ញាធរមូលដ្ឋាន។ ជាក់ស្តែងមានវិវាទដីធ្លីចំនួន ១៣ករណី ក្នុងចំណោម ១៨ករណីខាងលើ មានជាប់ពាក់ព័ន្ធជាមួយអាជ្ញាធរមូលដ្ឋាន ដែលអាចមានការប្រើប្រាស់អំណាចនៅក្នុងការគំរាមកំហែង។ ហើយវិវាទដីធ្លី ៥ករណីផ្សេងទៀត បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។

លើសពីនេះទៅទៀត ករណីវិវាទដីធ្លីដែលកើតមានក្នុងខេត្តកំពត និងខេត្តកែប ភាគគីវិវាទក៏មិនបានដាក់បណ្តឹងចូលទៅអាជ្ញាធរមូលដ្ឋានដែរ ដោយបានដាក់ពាក្យបណ្តឹងទៅសាលាខេត្តតែម្តង។

បន្ទាប់ពីអាជ្ញាធរមូលដ្ឋាន សាលាខេត្តជាប់ចំណាត់ទី២ ដែលបានទទួលពាក្យបណ្តឹងច្រើន ដោយមានពាក្យបណ្តឹងចំនួន ១៥៥បណ្តឹង ឬស្មើរនឹង ៥០ភាគរយនៃវិវាទទាំង៣០៨ករណី។ ក្នុងនោះ ២០ករណីក្នុងចំណោម ២៤ករណីក្នុងខេត្តបន្ទាយមាន

ជ័យ បានពាក្យបណ្តឹទៅសាលាខេត្ត។

ល.រ	ខេត្ត	ករណីវិវាទដីធ្លីដែលបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ ២០១៥	ពាក្យបណ្តឹងដែលបានដាក់ជូនទៅអាជ្ញាធរមូលដ្ឋាន	ភាគរយ (%)	ពាក្យបណ្តឹងដែលបានដាក់ជូនទៅអាជ្ញាធរខេត្ត	ភាគរយ (%)
១	បន្ទាយមានជ័យ	២៤	១៤	៥៨	២០	៨៣
២	បាត់ដំបង	២០	៨	៤០	១០	៥០
៣	កំពង់ចាម	១០	៧	៧០	១	១០
៤	កំពង់ឆ្នាំង	៨	៨	១០០	៤	៥០
៥	កំពង់ស្ពឺ	២០	១៥	៧៥	១១	៥៥
៦	កំពង់ធំ	៦	៥	៨៣	៤	៦៧
៧	កំពត	៣	០	០	៣	១០០
៨	កណ្តាល	៥	២	៤០	៣	៦០
៩	កោះកុង	១៦	៥	៣១	៨	៥០
១០	ក្រចេះ	៧	៤	៥៧	៣	៤៣
១១	កែប	១	០	០	១	១០០
១២	មណ្ឌលគិរី	១៦	១៦	១០០	១២	៧៥
១៣	ឧត្តរមានជ័យ	៨	៦	៧៥	៥	៦៣
១៤	ភ្នំពេញ	២៨	២២	៧៩	១២	៤៣
១៥	ព្រះវិហារ	១៨	១៦	៨៩	១១	៦១
១៦	ព្រៃវែង	៩	៦	៦៧	២	២២
១៧	ពោធិ៍សាត	១៥	១១	៧៣	៤	២៧
១៨	ប៉ៃលិន	៣	១	៣៣	២	៦៧
១៩	ព្រះសីហនុ	២០	១១	៥៥	១១	៥៥

២០	រតនគិរី	២៤	២១	៨៨	១២	៥០
២១	សៀមរាប	១៣	៧	៥៤	៦	៤៦
២២	ស្ទឹងត្រែង	៤	១	២៥	១	២៥
២៣	ស្វាយរៀង	១៨	៣	១៧	៧	៣៩
២៤	តាកែវ	៣	២	៦៧	០	០
២៥	ត្បូងឃ្មុំ	៩	៧	៧៨	២	២២
សរុប		**៣០៨**	**១៩៨**	**មធ្យម ៥៨**	**១៥៥**	**មធ្យម ៥៨**

តារាងទី ៤៖ ពាក្យបណ្តឹងដែលបានដាក់ជូនទៅអាជ្ញាធរដែន និងសាលាខេត្ត

ស្ថាប័ន	**ចំនួនពាក្យបណ្តឹង**
អាជ្ញាធរមូលដ្ឋាន	១៩៨
គណៈកម្មការសុរិយោដីថ្នាក់ស្រុក	៣៤
គណៈកម្មការសុរិយោដីថ្នាក់ខេត្ត	៣៧
គណៈកម្មការសុរិយោដីថ្នាក់ជាតិ	៨
អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី	២២
សាលាដំបូងរាជធានី/ខេត្ត	៧៦
សាលាឧទ្ធរណ៍	៣១

តុលាការកំពូល	១៧
រដ្ឋសភា	៦៤
ព្រះបរមរាជវាំង	៦
ក្រសួងមហាផ្ទៃ	៣៣
ទីស្តីការគណៈរដ្ឋមន្ត្រី	២០
ខុទ្ទការល័យនាយករដ្ឋមន្ត្រី	៤២
សាលារាជធានី/ខេត្ត	១៥៤
ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច	២៥
អង្គការក្រៅរដ្ឋភិបាល (អាដហុក, សីអិលអឹសី, អាសីអេសអូ, លីការដូរ, វីជីឡែន, អង្គការសមាគមន៍ខ្មែរលើ,យូអិន, អាយឡូ)	៧២
ផ្សេងៗ	៤៩
សរុប	**៨៨៤**

តារាងទី ៥៖ ស្ថាប័នដែលទទួលពាក្យបណ្តឹង

៥.៤.២ ដំណើរការដោះស្រាយ

ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ វិវាទដីធ្លីចំនួន ៣០៨ ករណី បានឆ្លងកាត់កិច្ចដំណើរការដោះស្រាយ និងត្រូវបានដោះស្រាយចប់ពេញលេញទាំងស្រុង ឬត្រូវបានដោះស្រាយដោយផ្នែក ឬកិច្ចដំណើរការដោះស្រាយនៅកំពុងបន្ត។

ដូចដែលបានលើកឡើងនៅក្នុងចំណុចទី៥.៣ខាងលើ មាន ២១ករណី បានដោះស្រាយចប់ពេញលេញទាំងស្រុង។ វិវាទទាំងនេះ បានដាក់ពាក្យបណ្តឹងជូនទៅស្ថានប័នផ្សេងៗគ្នា ដូចជា អាជ្ញាធរមូលដ្ឋាន សាលាខេត្ត គណៈកម្មការសុរិយោដីខេត្ត គណៈកម្មការសុរិយោដីថ្នាក់ជាតិ នាយករដ្ឋមន្ត្រី តុលាការទាំងបីកម្រិត (សាលាដំបូងរាជធានី/ខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល) ក្រសួងការពារជាតិ គណៈកម្មការចំរុះថ្នាក់ខេត្ត មន្ទីកសិកម្មរុក្ខាប្រមាញ់និងនេសាទ និង ក្រសួងបរិស្ថាន។ ប៉ុន្តែលទ្ធផលនៃការដោះស្រាយវិវាទដីធ្លី គឺខុសៗគ្នា ពីករណីមួយ ទៅករណីមួយ។ ដោយយោងតាមមូលដ្ឋានទិន្នន័យ របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា មាន ១៥ករណី បានដោះស្រាយឲ្យម្ចាស់ដីដើម ជាអ្នកឈ្នះ ហើយមាន ៣ករណីដោះស្រាយ ជាលក្ខណៈសម្រមសម្រួល រវាងអ្នកកាន់កាប់ដីដើម និងភាគីទី២នៃវិវាទ។ ចំណែកឯ២ករណី ដោះស្រាយដោយឲ្យភាគីទីពីរនៃវិវាទជាអ្នកឈ្នះ និង ១ករណីផ្សេងទៀត ដំណោះស្រាយដោយការទូរទាត់ជាសំណង។

ឯកសារដែលប្រើប្រាស់ជាការសំអាងក្នុងការទាមទារដីដោយភាគីទាំងសងខាងនៃវិវាទ រួមមាន ការសំអាងតាមរយៈការតាំងលំនៅឋានមិនរៀបរយ សិទ្ធិជាប្រពៃណីជនជាតិដើមភាគតិច លិខិតទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច កិច្ចសន្យារុករករ៉ែ ឯកសារកម្មសិទ្ធិមិនផ្លូវការ ផែនទីគម្របព្រៃឆ្នាំ២០០២ និងការដឹងឮដោយប្រជាជនដែលរស់នៅជុំវិញ (សូមមើលតារាង)។

ល.រ	ខេត្ត	ស្ថានភាពវិវាទ	ឯកសារដែលដើមបណ្តឹងប្រើប្រាស់	ឯកសារដែលចុងបណ្តឹងប្រើប្រាស់
៦៥៦	បន្ទាយមានជ័យ	ដោះស្រាយឲ្យភាគីទាំងដើមបណ្តឹង និងចុងបណ្តឹង	ការតាំងលំនៅឋានមិនរៀបរយ, សិទ្ធប្រពៃរបស់ជនជាតិដើមភាគតិច, លិខិតដែលទទួលស្គាល់ដោអាជ្ញាធរ,	ការតាំងលំនៅឋានមិនរៀបរយ, លិខិតទទួលស្គាល់ពីអាជ្ញាធរ, ឯកសារមិនផ្លូវការ
២១៧៤	បន្ទាយមានជ័យ	ដោះស្រាយទៅឲ្យដើមបណ្តឹង		ផែនទីគំរប់ព្រៃឈើឆ្នាំ ២០០២
២៥០២	បន្ទាយមានជ័យ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការដឹងឮជាសាធារណៈដោយប្រជាពលរដ្ឋក្នុងតំបន់	ប្រើអំណាចជាទាហាន
២៥១៤	បន្ទាយមានជ័យ	ដោះស្រាយទៅឲ្យដើមបណ្តឹង	លិខិតទទួលស្គាល់ពីអាជ្ញាធរ	ផែនទីគំរប់ព្រៃឈើឆ្នាំ ២០០២
២២៩២	កំពង់ស្ពឺ	ដោះស្រាយឲ្យភាគីទាំងដើមបណ្តឹង និងចុងបណ្តឹង	លិខិតទទួលស្គាល់ពីអាជ្ញាធរ	កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
២៧២៨	កំពង់ធំ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការតាំងលំនៅឋានមិនរៀបរយ, សិទ្ធប្រពៃរបស់ជនជាតិដើមភាគតិច,	កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

២៥៧៣	មណ្ឌលគិរី	ដោះស្រាយឲ្យភាគីទាំងដើមបណ្តឹង និងចុងបណ្តឹង	ការតាំងលំនៅឋានមិនរៀបរយ, សិទ្ធប្រពៃណីរបស់ជនជាតិដើមភាគតិច,	ផែនទីគំរប់ព្រៃឈើឆ្នាំ ២០០២
២២០៤	រាជធានីភ្នំពេញ	ដោះស្រាយទៅឲ្យដើមបណ្តឹង	កិច្ចសន្យាលក់/ទិញ	
២២០៩	រាជធានីភ្នំពេញ	ដោះស្រាយទៅឲ្យចុងបណ្តឹង	គ្មានព័ត៌មាន	គ្មានព័ត៌មាន
២៧០៣	រាជធានីភ្នំពេញ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការតាំងលំនៅឋានមិនរៀបរយ	ដីរដ្ឋ
២២៤៨	ព្រះវិហារ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការតាំងលំនៅឋានមិនរៀបរយ, លិខិតកាន់កាប់បណ្តោះអាសន្ន	កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
២២៤៩	ព្រះវិហារ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ផែនទី និងនិយាមការនៃការកំណត់ព្រំប្រទល់	ដីរដ្ឋសំរាប់បន្ទាយទាហាន
២៧៤៣	ព្រះវិហារ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការតាំងលំនៅឋានមិនរៀបរយ	កិច្ចសន្យារ៉ុករកអ៊ែ
២៧៤៤	ព្រះវិហារ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការតាំងលំនៅឋានមិនរៀបរយ	កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
២៨០៩	ព្រះវិហារ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការតាំងលំនៅឋានមិនរៀបរយ	កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
២៧៤០	ព្រៃវែង	ដោះស្រាយទៅឲ្យដើមបណ្តឹង	គ្មានព័ត៌មាន	គ្មានព័ត៌មាន

២៧៤២	ព្រៃវែង	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការកាន់កាប់ដោយដឹងឮជាសាធារណៈដោយអាជ្ញាធរ និងប្រជាពលរដ្ឋជុំវិញ	ការប្រើប្រាស់អំណាច
២៤៩៥	រតនគិរី	ដោះស្រាយទៅឲ្យដើមបណ្តឹង	សិទ្ធប្រពៃរបស់ជនជាតិដើមភាគតិច	ប្រើអំណាចជាទាហាន
២៨៨៩	ព្រះសីហនុ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការតាំងលំនៅឋានមិនរៀបរយ, សិទ្ធប្រពៃរបស់ជនជាតិដើមភាគតិច,	កិច្ចសន្យាសម្បទានដី
២៨៩០	ព្រះសីហនុ	ដោះស្រាយទៅឲ្យដើមបណ្តឹង	ការតាំងលំនៅឋានក្រៅផ្លូវការ	
២៦៦១	ត្បូងឃ្មុំ	ដោះស្រាយដោយសំណង	ការប្រើប្រាស់ជាក់ស្តែង	ការប្រើប្រាស់អំណាច

តារាងទី ៦៖ ឯកសារដែលប្រើប្រាស់សម្រាប់ការទាមទារយកដីដោយភាគីនៃវិវាទដីធ្លី

បន្ថែមពីនេះ វិវាទដីធ្លី ចំនួន ២៨៧ករណីដែលកំពុងបន្តរងចាំដំណោះស្រាយ មាន ១៥៤ករណី មិនទាន់បានដោះស្រាយ ខណៈដែល ១២៤ករណី ដោះស្រាយបានមួយផ្នែក (ឧទាហរណ៍: វិវាទដីធ្លីដែលជាប់ពាក់ព័ន្ធច្រើនគ្រួសារ ប៉ុន្តែមានគ្រួសារមួយចំនួនក្នុងចំណោមគ្រួសារទាំងនោះ ត្រូវបានដោះស្រាយរួចរាល់)។ វិវាទដីធ្លី ចំនួន ២ករណី បានបោះបង់ចោលដោយភាគីវិវាទ។ ចំណែកឯវិវាទដីធ្លី ចំនួន ៧ករណី មានសភាព "ស្ងៀមស្ងាត់"។

ប្រជាពលរដ្ឋរងផលប៉ះពាល់ បានចំណាយពេលវេលាក្នុងការធ្វើយុទ្ធនាការតស៊ូមតិជាច្រើនជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ ហើយពួកគាត់មិនត្រូវបានអនុញ្ញាតិឲ្យប្រើប្រាស់ដីដែលកំពុងមានវិវាទនោះទេ។ ប្រការនេះ ធ្វើឲ្យពួកគាត់មិនអាចដាំដុះ

ដំណាំ ធ្វើស្រែចំការ ប្រមូលអនុផលព្រៃឈើ និងប្រកបមុខរបរប្រចាំជីវិតបានងាយស្រួលឡើយ ទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់ជីវភាពគ្រួសារហើយកូនៗរបស់ពួកគាត់ខ្វះភាពកក់ក្តៅ។ ជាក់ស្តែងតាមប្រភពសារព័ត៌មាន ដែលវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ទទួលបាន និងកត់ត្រាក្នុងទិន្នន័យឆ្នាំ២០១៥នេះ មានការធ្វើយុទ្ធនាការ/ការប្រមូលផ្តុំ ចំនួន ៩៦លើក ដើម្បីនាំយកពាក្យបណ្តឹងវិវាទដីធ្លី ដាក់ទៅអាជ្ញាធរ ក្រសួង ក៏ដូចជាថ្នាក់ដឹកនាំកំពូលរបស់រដ្ឋាភិបាលកម្ពុជា។

ដំណើរការដោះស្រាយវិវាទដីធ្លី	ចំនួនករណីវិវាទដីធ្លី	ភាគរយ (%)
មិនទាន់ដោះស្រាយ	១៥៤	៥០
ដោះស្រាយបានមួយផ្នែក	១២៤	៤០
ដោះស្រាយទៅឲ្យចុងបណ្តឹង	២	១
ដោះស្រាយទៅឲ្យដើមបណ្តឹង	១៥	៥
ដោះស្រាយទៅឲ្យភាគីទាំងដើមបណ្តឹង និងចុងបណ្តឹង	៣	១
ដោះស្រាយដោយសំណង	១	០
វិវាទត្រូវបានបោះបង់ចោល	២	១
វិវាទ "ស្ងប់ស្ងាត់ "	៧	២
សរុប	**៣០៨**	**១០០**

តារាងទី ៧៖ ដំណើការដោះស្រាយវិវាទដីធ្លី

ខេត្ត	ចំនួនយុទ្ធនាការ
កោះកុង	៨
ភ្នំពេញ	៣៣
បាត់ដំបង	៩
សៀមរាប	៥
ស្វាយរៀង	១
កំពង់ឆ្នាំង	៦
រតនគិរី	៥
បន្ទាយមានជ័យ	៦
ពោធិ៍សាត	២
កំពង់ធំ	១
មណ្ឌលគិរី	៤
កណ្តាល	៣
ក្រចេះ	៧
ត្បូងឃ្មុំ	១
ព្រះវិហារ	២
កំពត	១
ស្ទឹងត្រែង	១
ព្រះសីហនុ	១
សរុប	**៩៦**

តារាងទី៨: យុទ្ធនាការ/ការប្រមូលផ្តុំក្នុងការតស៊ូមតិអំពីវិវាទដីធ្លីតាមបណ្តាខេត្ត/រាជធានី

ក្រុមគ្រួសារនៃសហគមន៍ដែលរងផលប៉ះពាល់មកពីស្រុកចំនួន ២ គឺស្រុកតំបែរ និងស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានប្រមូលផ្តុំគ្នានៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីដាក់ពាក្យបណ្តឹងរបស់ពួកគេជូនដល់ក្រសួង ដ.ន.ស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ខុទ្ទកាល័យនាយករដ្ឋមន្ត្រី អង្គភាពប្រឆាំងអំពើពុករលួយ ព្រមទាំងរដ្ឋសភា ដើម្បីទាមទារឲ្យមានការដោះស្រាយបញ្ហាវិវាទដីធ្លីរបស់ពួកគេ

ថតដោយ៖ លោក វង្ស កុសល់

កាលបរិច្ឆេទ៖ ២៧ មេសា ២០១៦

សហគមន៍ជនជាតិដើមភាគតិចព្នង មកពីឃុំស្រែឈូក ស្រុកពេជ្រាដា ខេត្តមន្ទលគិរី ប្រហែល ៥៧ នាក់ បានប្រមូលផ្តុំគ្នានៅមុខសាលាខេត្តមណ្ឌលគិរីដើម្បីទាមទារឲ្យរាជរដ្ឋាភិបាលដោះស្រាយវិវាទរបស់ពួកគាត់ជាមួយនឹងក្រុមហ៊ុន ប៊ិញ ភឹក (វៀតណាម)។

ថតដោយ៖ លោក សុក រដ្ឋា

កាលបរិច្ឆេទ: ៣០ ឧសភា ឆ្នាំ ២០១៦

៥.៤.៣ ស្ថាប័នដែលដោះស្រាយវិវាទដីធ្លីក្នុងឆ្នាំ២០១៥

ផ្អែកតាមទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋភិបាលស្តីពីកម្ពុជា ទទួលបាន វិវាទដីធ្លីសរុបដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ ២០១៥ មានចំនួន ២១ករណី បានកើតឡើងនៅក្នុងខេត្ត ចំនួន១០ គឺខេត្តព្រះវិហាមាន៥ ករណី បន្ទាយមានជ័យមាន៤ករណី រាជធានីភ្នំពេញមាន៣ករណី ព្រៃវែងមាន២

ករណី ព្រះសីហានុមាន២ករណី និង កំពង់ស្ពឺ កំពង់ធំ មណ្ឌលគិរី រតនគិរី និងត្បូងឃ្មុំ មាន១ករណីដូចគ្នា។

ករណីវិវាទដីធ្លីទាំង២១នេះ បានដាក់ពាក្យបណ្តឹងទៅកាន់ស្ថាប័នផ្សេងៗជាច្រើន សរុបពាក្យបណ្តឹងមានចំនួន ៣៩បណ្តឹង។ ស្ថាប័នទាំងនោះ មានដូចជា អាជ្ញាធរមូលដ្ឋាន(ឃុំ/ស្រុក)ទទួលបាន១៧បណ្តឹង អាជ្ញាធរខេត្ត/ក្រុងទទួលបាន៩បណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ខេត្តទទួលបាន៣បណ្តឹង សាលាដំបូងខេត្តទទួលបាន៥បណ្តឹង សាលាឧទ្ធរណ៍ទទួលបាន១បណ្តឹង តុលាការកំពូលទទួលបាន១បណ្តឹង អាជ្ញាធរដោះស្រាយវិវាទដីធ្លីថ្នាក់ជាតិទទួលបាន ៣បណ្តឹង ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទទួលបាន១បណ្តឹង។ ដំណោះស្រាយភាគច្រើន ធ្វើឡើងជាលក្ខណៈសហការរវាងស្ថាប័ន/មន្ទីរដែលពាក់ព័ន្ធតាមបណ្តាខេត្តនិមួយៗ ពេលខ្លះស្ថាប័នដែលបានទទួលពាក្យបណ្តឹង មិនមែនជាស្ថាប័នដោះស្រាយវិវាទចុងក្រោយឡើយ។ ជាក់ស្តែងវិវាទដីធ្លីចំនួន ១២ករណី ត្រូវបានដោះស្រាយដោយគណៈកម្មការចម្រុះក្នុងខេត្ត ក្នុងនោះក៏មានការចូលរួមចំណែកមួយភាគធំចេញពីការអនុវត្តបទបញ្ជា០១ផងដែរ ដោយបានវាស់វែងនិងសម្របសម្រួលនាកំឡុងឆ្នាំ២០១២ និង២០១៣។ ជាមួយគ្នានេះ អាជ្ញាធរមូលដ្ឋានឃុំ/សង្កាត់ បានដោះស្រាយវិវាទចប់ពេញលេញ ចំនួន ៣ករណី, អាជ្ញាធរខេត្តបានដោះស្រាយវិវាទបញ្ចប់ចំនួន ២ករណី, សាលាក្រុងបានដោះស្រាយវិវាទដីធ្លីចប់ចំនួន ៣ករណី ។

ដោយឡែក យើងក៏ឃើញមានករណីវិវាទដីធ្លី ១ករណី (លេខ២៨៩០) កើតឡើង រវាងប្រជាសហគមន៍ចំនួន ៨៦គ្រួសារ ជាមួយអង្គភាពមូលដ្ឋានសមុទ្រាមលើផ្ទៃដី២,៧៦ហិចតា និងភាគីវិវាទម្ខាងទៀតគឺក្រុមហ៊ុនយិះជៀរ ពាក់ព័ន្ធនឹងផ្លូវចេញចូលរបស់ប្រជាពលរដ្ឋឆ្លងកាត់តំបន់ក្រុមហ៊ុនយិះជៀរ។ ករណីនេះ បានដាក់ពាក្យបណ្តឹងទៅសាលាខេត្ត។ ការដោះស្រាយលើករណីវិវាទមានពីរផ្នែកផ្សេងគ្នា ផ្នែកដែលប៉ះពាល់ជាមួយអង្គភាពមូលដ្ឋានសមុទ្រាម គឺអង្គភាពមូលដ្ឋានសមុទ្រាម

ផ្ទាល់ជាអ្នកដោះស្រាយដោយធ្វើការប្តូរទីតាំងសហគមន៍ទៅប្តូកមួយទៀតដែលស្ថិតនៅក្នុងតំបន់មូលដ្ឋានសមុទ្ររាមដដែល។ ចំណែកឯផ្នែកដែលប៉ះពាល់ជាមួយក្រុមហ៊ុន យិះជៀរ សាលាខេត្តព្រះសីហនុ ជាអ្នកដោះស្រាយសម្របសម្រួលរវាងក្រុមហ៊ុន និងប្រជាពលរដ្ឋដោយភាគីក្រុមហ៊ុន ព្រមទទួលខុសត្រូវលើការសាងសង់ផ្លូវថ្មីមួយខ្សែប្រវែង ១៤០០ម៉ែត្រ ស្របតាមបណ្តាយព្រំប្រទល់របស់ក្រុមហ៊ុនដើម្បីបញ្ចៀសការឆ្លងកាត់ក្នុងតំបន់របស់ក្រុមហ៊ុន។

ដំណោះស្រាយវិវាទដីធ្លីផ្សេងទៀត ដែលបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចំនួន៥ករណី ក្នុងចំណោមករណីវិវាទដីធ្លីទាំង២១ករណី បានដោះស្រាយចប់ពេញលេញទាំងស្រុង ដែលការដោះស្រាយធ្វើឡើងតាមរយៈគណៈកម្មការចម្រុះក្នុងខេត្ត និងមានការចូលរួមចំណែកមួយភាគធំចេញពីការអនុវត្តបទបញ្ជា០១។ ជាក់ស្តែង វិវាទដីធ្លីលេខ ២២៤៨ ប្រជាពលរដ្ឋ ចំនួន៤៥គ្រួសារ ក្នុងភូមិស្រយ៉ងខាងជើង ឃុំស្រយ៉ង ស្រុកគូលេន ខេត្តព្រះវិហារ មានទំនាស់ជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចឈ្មោះ សីលាដាមិច (Seila Damix)។ ករណីនេះដោះស្រាយដោយអភិរងបាលខេត្ត រួមជាមួយប្រធានមន្ទីរវៀបចំដែនដីនគរូបនីយកម្មសំណង់និងសុរិយោដីនាយរដ្ឋបាលព្រៃឈើខេត្តព្រះវិហារ និងមន្ទីរពាក់ព័ន្ធមួយចំនួនទៀត។ គណៈកម្មការចម្រុះក្នុងខេត្ត បានចុះទៅដល់ទីកន្លែងកើតហេតុ ហើយបានសម្របសម្រួលវៀបចំកិច្ចប្រជុំជាមួយតំណាងក្រុមហ៊ុន និងគ្រួសារសហគមន៍ដែលរងផលប៉ះពាល់។ ជាលទ្ធផលយើងឃើញថា ក្រុមហ៊ុនឯកភាពប្រើរូបមន្តស្បែកខ្លាដោយឆ្វៀលចេញនូវដីប្រជាពលរដ្ឋដែលកំពុងកាន់កាប់ជាក់ស្តែង។

ល.រ	ខេត្ត	ស្រុក	ឃុំ	# គ្រួសារងងលប៉ះពាល់	ទំហំវិវាទ	ប្រភេទដី	ឆ្នាំ	ស្ថានភាពនៃដំណោះស្រាយវិវាទ	ស្ថាប័នដែលដោះស្រាយវិវាទ
៦៥៦	បន្ទាយមានជ័យ	ភ្នំស្រុក	ប៉ោយចារ	២០០	៦០០	ដីព្រៃ-ដីរដ្ឋ	១៩៩៩	ដោះស្រាយឲ្យទៅដើមបណ្តឹង និងចុងបណ្តឹង	សាលាខេត្ត
២១៧៤	បន្ទាយមានជ័យ	ថ្មពួគ	ថ្មពួគ	២៥០	២១៥	ដីចំការ	២០០៨	ដោះស្រាយឲ្យដើមបណ្តឹង	គណៈកម្មការចម្រុះខេត្ត
២៥០២	បន្ទាយមានជ័យ	ថ្មពួគ	ថ្មពួគ	៨៣	១១៥	ដីស្រែរដូវវស្សា	២០០៥	ដោះស្រាយឲ្យដើមបណ្តឹង	គណៈកម្មការចម្រុះខេត្ត
២៥១៤	បន្ទាយមានជ័យ	ស្វាយចេក	តាប៉ែន	១៤៥	១៥០០	ដីចំការ	២០១០	ដោះស្រាយឲ្យដើមបណ្តឹង	គណៈកម្មការចម្រុះខេត្ត
២២៩២	កំពង់ស្ពឺ	ភ្នំស្រួច		១១១	៥០០	ដីប្រើប្រាស់សំរាប់បំណាងច្រើនយ៉ាង	២០០៧	ដោះស្រាយទៅឲ្យភាគីទាំងសងខាងនៃវិវាទ	គណៈកម្មការចម្រុះខេត្ត
២៧២៨	កំពង់ធំ	សណ្តាន់	ង៉ន	៣០	១០០	ដីចំការ	២០១២	ដោះស្រាយឲ្យដើមបណ្តឹង	គណៈកម្មការចម្រុះខេត្ត
២៥៧៣	មណ្ឌលគិរី	អូរាំង	ដាក់ដាំ	៥២	២០០០	ដីចំការ	២០១០	ដោះស្រាយទៅឲ្យភាគីទាំងសងខាងនៃវិវាទ	គណៈកម្មការចម្រុះខេត្ត

២២០៤	រាជធានីភ្នំពេញ	ឫស្សីកែវ	ឃ្មួញ	២៣	១	ដីភូមិ/ដីលំនៅឋាន	២០០៨	ដោះស្រាយឲ្យដើមបណ្តឹង	សាលាក្រុង
២២០៩	រាជធានីភ្នំពេញ	ឫស្សីកែវ	ទួសង្កែ	១២	១	ដីភូមិ/ដីលំនៅឋាន	២០០៨	ដោះស្រាយទៅឲ្យចុងបណ្តឹងឈ្នះ	សាលាក្រុង
២៧០៣	រាជធានីភ្នំពេញ	ឫស្សីកែវ	ជ្រោយចង្វា	១៦៨		ដីច្រាំងទន្លេ	២០០៨	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	សាលាក្រុង
២២៤៨	ព្រះវិហារ	គូលេន	ស្រយ៉ង	៤៥	២១៩	ដីប្រើប្រាស់សំរាប់បំណងច្រើនយ៉ាង	២០០៩	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	គណៈកម្មការចម្រុះខេត្ត
២២៤៩	ព្រះវិហារ	គូលេន	ស្រយ៉ង	៦៥	៥០	ដីប្រើប្រាស់សំរាប់បំណងច្រើនយ៉ាង	២០១១	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	គណៈកម្មការចម្រុះខេត្ត
២៧៤៣	ព្រះវិហារ	រវៀង	រំដោះ	២៧២	១២៨៦	ដីចំការ	២០១៣	ដោះស្រាយទៅឲ្យចុងបណ្តឹងឈ្នះ	គណៈកម្មការចម្រុះខេត្ត
២៧៤៤	ព្រះវិហារ	គូលេន	ស្រយ៉ង	៥០	២៥០	ដីចំការ	២០១៣	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	គណៈកម្មការចម្រុះខេត្ត
២៨០៩	ព្រះវិហារ	រវៀង	រម្មណីយ	១៥០	២២៩	ដីប្រើប្រាស់សំរាប់បំណងច្រើនយ៉ាង	២០១៤	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	គណៈកម្មការចម្រុះខេត្ត

២៧៤០	ព្រៃវែង	ព្រះស្តេច	រាធរ	២០០	៣១៥	ដីប្រឡាយទឹក	២០១០	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	គណៈកម្មការចម្រុះខេត្ត
២៧៤២	ព្រៃវែង	កំពង់ត្របែក	គោខ្លក	៤២	០,០០៧៦	ស្រះទឹកសាធារណៈ	២០០៩	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	អាជ្ញាធរមូលដ្ឋាន
២៤៩៦	រតនគិរី	លំផាត់	បាតាង	២០	១០០	ដីប្រើប្រាស់សំរាប់បំណងច្រើនយ៉ាង	២០១១	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	អាជ្ញាធរមូលដ្ឋាន
២៨៨៩	ព្រះសីហនុ	ព្រៃនប់		៣៤៣	៤៣៣,៣៩	ដីភូមិ/ដីលំនៅឋាន	២០០៧	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	អាជ្ញាធរមូលដ្ឋាន
២៨៩០	ព្រះសីហនុ	ព្រៃនប់	រាម	៤៦	២,៧៦	ដីភូមិ/ដីលំនៅឋាន	២០០៧	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	ទារហានជើងទឹកប្រចាំការនៅរាម
២៦៦១	ត្បូងឃ្មុំ	មេមត់	រូង	៧០០	១០០	ដីស្រែរដូវវស្សា	១៩៩៩	ដោះស្រាយទៅឲ្យដើមបណ្តឹងឈ្នះ	សាលាខេត្ត

តារាងទី ៩៖ ស្ថាប័នដែលដោះស្រាយវិវាទដីធ្លី

៥.៥ គ្រួសារដែលរងផលប៉ះពាល់ពីវិវាទដីធ្លី

វិវាទដីធ្លីចំនួន ២៨៥ករណី កំពុងបន្តរងចាំដំណោះស្រាយ បានប៉ះពាល់ដល់ប្រជាពលរដ្ឋ ចំនួន ៤៨,០៥១.០០គ្រួសារ និងប្រមាណជា ២២១,០៣៥.០០នាក់(ជាមធ្យមក្នុងមួយគ្រួសារមាន៤,៦នាក់ [15]) ចំនួននេះស្មើរនឹង១,៦០ភាគរយនៃចំនួនគ្រួសារសរុបទូទាំងប្រទេស។ ចំនួននេះមិនរាប់បញ្ចូលនូវវិវាទដីធ្លីចំនួន ២៣ករណី ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ២,៩៧៧.០០គ្រួសារ ត្រូវបានដោះស្រាយចប់ពេញលេញទាំងស្រុង។

ល.រ	ខេត្ត	#ករណីវិវាទដីធ្លីដែលកំពង់បន្តក្នុងឆ្នាំ២០១៥	#គ្រួសាររងផលប៉ះពាល់
១	បន្ទាយមានជ័យ	២០	៣១០៦
២	បាត់ដំបង	២០	១៦៥០
៣	កំពង់ចាម	១០	១២១៨
៤	កំពង់ឆ្នាំង	៨	១១៩៨
៥	កំពង់ស្ពឺ	១៩	២៦៦៥
៦	កំពង់ធំ	៥	៥៣៨
៧	កំពត	៣	១០០
៨	កណ្តាល	៥	១២១៣
៩	កែប	១	១៥
១០	កោះកុង	១៦	២៣០៥
១១	ក្រចេះ	៧	២៥៥១

[15] Cambodia Inter-Censal Population Survey 2013 (CIPS), Pg. 5, available at http://www.stat.go.jp/info/meetings/cambodia/pdf/ci_pr02.pdf

១២	មណ្ឌលគិរី	១៥	៤២៩៧
១៣	ឧត្តរមានជ័យ	៨	១៩២៧
១៤	ប៉ៃលិន	៣	៥១១
១៥	រាជធានីភ្នំពេញ	២៥	៦០៧៨
១៦	ព្រះសីហនុ	១៨	២០៦៧
១៧	ព្រះវិហារ	១៣	១៣៦៩
១៨	ព្រៃវែង	៧	៤៥០១
១៩	ពោធិ៍សាត់	១៤	២៦៧២
២០	រតនគិរី	២២	២៤១៥
២១	សៀមរាប	១៣	១១០៦
២២	ស្ទឹងត្រែង	៤	១៦២
២៣	ស្វាយរៀង	១៨	២១៣៩
២៤	តាកែវ	៣	១១៤
២៥	ត្បូងឃ្មុំ	៨	២១៣៤
សរុប		**២៨៥**	**៤៨០៥១**

តារាងទី១០៖ គ្រូសារដែលរងផលប៉ះពាល់ដោយសារវិវាទដីធ្លីតាមបណ្តាខេត្ត

តារាងជារង្វង់ខាងក្រោមបង្ហាញថា រាជធានីភ្នំពេញមានចំនួនប្រជាជនចំនួន ៦,០៧៨.០០គ្រួសារ រងផលប៉ះពាល់ដោយសារវិវាទដីធ្លីខ្ពស់ជាងគេ បន្ទាប់មកខេត្តព្រៃវែងមានចំនួន ៤,៥០១.០០គ្រួសារ។ ផ្ទុយទៅវិញ ខេត្តកែបគឺជាខេត្តដែលមានប្រជាពលរដ្ឋរងផលប៉ះពាល់តិចជាងគេមានតែ១៥គ្រួសារប៉ុណ្ណោះ។



រូបទី ៥៖ គ្រួសារដែលរងផលប៉ះពាល់ដោយសារវិវាទដីធ្លីតាមបណ្តាខេត្ត

របាយការណ៍នេះបង្ហាញថា ករណីវិវាទដីធ្លីចំនួន ១៥១ករណី ស្មើរនឹង៥៣ ភាគរយនៃករណីវិវាទដែលកំពុងបន្ត(២៨៥ករណី) ពាក់ព័ន្ធចាប់ពី ៥គ្រួសារ ទៅ ១០០គ្រួសារ ប៉ះពាល់ដល់៧,១៤០.០០គ្រួសារ។ ករណីវិវាទចំនួន ៧១ករណី ស្មើរ នឹង២៥ភាគរយ ពាក់ព័ន្ធចាប់ពី១០១គ្រួសារ ទៅ២០០គ្រួសារ ប៉ះពាល់ដល់ ១០,៥១១.០០គ្រួសារ ក្នុងនោះមាន ៣៣ករណី បង្ករឡើងដោយក្រុមហ៊ុនសម្បទាន ដីសង្គមកិច្ច សម្បទានរុករក ឬដកហូតដែ ការធ្វើបន្ទាយទាហាន ក្រុមហ៊ុនឯកជន និងការផ្តល់សម្បទានដីសង្គមកិច្ច។

មានករណីវិវាទដីធ្លីចំនួន ៧ករណី ស្មើនឹង២ភាគរយ ដោយករណីនិមួយៗ ជាប់ ពាក់ព័ន្ធចាប់ពី១០០០គ្រួសារឡើង ក្នុងនោះ ៣ករណី បង្ករឡើងដោយក្រុមហ៊ុន សម្បទានដីសេដ្ឋកិច្ច ៣ករណីជាប់ពាក់ព័ន្ធជាមួយដីរដ្ឋ និង១ករណីទៀតជាប់ពាក់ ព័ន្ធជាមួយការផ្តល់សម្បទានដី (ករណីលេខ ២៤៤៦ វិវាទរវាងប្រជាពលរដ្ឋចំនួន ១១៦៣គ្រួសារជាមួយនឹងក្រុមហ៊ុន UDG ដែលជាក្រុមហ៊ុនចិន)[16]។

លំដាប់គ្រួសារ	#វិវាទដីធ្លីដែលកំពង់បន្ត	ភាគរយ (%)	#គ្រួសារ
៥-១០០	១៥១	៥៣	៧១៤០
១០១-២០០	៧១	២៥	១០៤១១
២០១-៣០០	២៩	១០	៧១៦៧
៣០១-៤០០	១៣	៥	៤៥៧៤
៤០១-៥០០	៤	១	១៨០៦
៥០១-៦០០	២	១	១០៤៩

[16] ករណីលេខ ២៤៤៦ ជាវិវាទរវាងប្រជាពលរដ្ឋ ១១៦៣គ្រួសារ ជាមួយក្រុមហ៊ុនចិនដែលបានចុះកិច្ច សន្យាជាមួយរដ្ឋតិបាលកម្ពុជាសំរាប់វិនិយោគរយៈពេល ៩៩ ឆ្នាំនៅលើកោះរ៉ុង ។ ករណីនេះមាន ដំណោះស្រាយមួយចំនួនបានធ្វើឡើង ដោយផ្លាស់ប្តូរប្រជាពលរដ្ឋទៅទីតាំងថ្មី។ តែប្រជាពលរដ្ឋដែល មិនទទួលយកសំណងនេះនៅតែបន្តការតវ៉ា និងប្រជាពលរដ្ឋដែលឯកភាពក្នុងការផ្លាស់ប្តូរទីតាំងថ្មី ចំនួន ២០០ គ្រួសារ បានត្រឡប់កមទីតាំងវិវាទវិញ ហើយស្នើរសុំសំណងបន្ថែម នៅពេលដែលពួកគេ ដឹងថាប្រជាពលរដ្ឋ ១៩ គ្រួសារទទួលបានសំណងប្រសើរជាងសំណងដែលពួកគេបានទទួល

៦០១-៧០០	៤	១	២៧៣០
៧០១-៨០០	២	១	១៥០៤
៨០១-៩០០	០	០	០
៩០១-១០០០	១	០	៩៨៤
>១០០០	៧	២	១០៦៨៦
គ្មានព័ត៌មាន	១	០	០
សរុប	**២៨៥**	**១០០**	**៤៨០៥១**

តារាងទី ១១: ចំនួនគ្រួសាររងផលប៉ះពាល់ គិតតាមខេត្ត

៥.៦ ប្រភេទដីដែលរងផលប៉ះពាល់ពីទំនាស់ដីធ្លី

វិវាទដីធ្លីបានគ្រប់ដណ្តប់លើផ្ទៃដីទំហំ ៩៩៥,០១៧.៦០ហិចតា។ ផ្ទៃដីមានវិវាទទាំងនោះ ជាដីប្រើប្រាស់សំរាប់គោលបំណងជាច្រើន ដូចជា ដីកសិកម្ម (ដីចំការ និងដីស្រែ) ដីលំនៅឋាន/ភូមិករ ដីរដ្ឋ (ដីព្រៃសហគមន៍ ដីព្រៃ ដីច្រាំងទន្លេ ដីព្រៃលិចទឹក ស្រះរួម ដីសាលារៀន ដីឆ្នេរ ប្រឡាយ/ចំណីប្រឡាយ ផ្លូវដើរ ដីគ្រោងសម្រាប់ការពង្រីកប្រឡាយឬផ្លូវ ដីកប់ខ្មោចរួមរបស់ជនជាតិដើមភាគតិច ដីរួមរបស់ភូមិ/ឃុំ) ដីវត្ត និងដីដែលប្រើប្រាស់សំរាប់គោលបំណងច្រើនយ៉ាង។

តាមរយៈលទ្ធផលនៃការវិភាគទិន្នន័យបានបង្ហាញថា ដីលំនៅឋាន/ដីភូមិ គឺជាប្រភេទដីដែលជាកម្មវត្ថុនៃវិវាទដីធ្លីច្រើនជាងគេ ផ្ទៃដីសរុបនៃវិវាទមានចំនួន ៧៩១,០៣៥.៩០ហិចតា បន្ទាប់មកគឺដីដែលប្រើប្រាស់សម្រាប់គោលបំណងច្រើនយ៉ាង ផ្ទៃដីសរុបនៃវិវាទចំនួន ១២៣,២៨១.០០ហិចតា។ មានហេតុផលជាច្រើនដែលបង្ករឲ្យមានវិវាទដីធ្លីចំពោះដីលំនៅឋាន/ដីភូមិ ដូចជាការផ្តល់ដីសម្បទានដីសេដ្ឋកិច្ច ៨ករណី គោលបំណងសំរាប់រៀបចំបន្ទាយទាហាន(រួមទាំងបន្ទាយថ្មី និងបន្ទាយចាស់) ៨ករណី តំបន់អភិវឌ្ឍន៍របស់រដ្ឋដែលមានករណីវិវាទ ១០ករណី និងការវិ

និយោគរបស់គ្រុមហ៊ុនឯកជន ៥ករណី។



រូបទី ៥: ប្រភេទដីដែលរងផលប៉ះពាល់ពីវិវាទដីធ្លី

លើសពីនេះ យើងឃើញថា ទំហំផ្ទៃដីជាមធ្យមជាប់ពាក់ព័ន្ធជាមួយវិវាទដីធ្លីមានទំហំ៣,៤៤៤.១៨ហិចតា ខណៈផ្ទៃដីដែលជាប់ពាក់ព័ន្ធវិវាទដីធ្លីធំបំផុត មានទំហំ ៤៥,១០០.០០ហិចតា ដែលជាប្រភេទដីប្រើប្រាស់សំរាប់គោលបំណងច្រើនយ៉ាង ស្ថិតនៅក្នុងខេត្តកោះកុង និងជាវិវាទដីធ្លីរវាងប្រជាពលរដ្ឋចំនួន ១,១៦៣គ្រួសារ ជាមួយនឹងក្រុមហ៊ុន UDG ជាក្រុមហ៊ុនចិន (វិវាទលេខ២៤៤៦) ដែលទទួលបានកិច្ចសន្យាជួលរយៈពេលវែងពីរដ្ឋាភិបាលក្នុងឆ្នាំ២០០៨។ ករណីនេះបានប្រែក្លាយកាន់តែធ្ងន់ធ្ងរទៅៗ ចាប់តាំងពីឆ្នាំ២០១០ រហូតមកដល់ឆ្នាំ២០១៥។ ជាក់ស្តែងនៅថ្ងៃទី២០ មិនា ឆ្នាំ២០១១ បុគ្គលិកក្រុមហ៊ុន និងប៉ូលីសយោធា បានបំផ្លាញផ្ទះសំបែង និងដំណាំរបស់ប្រជាពលរដ្ឋ។ នៅថ្ងៃទី២៣ មករា ឆ្នាំ២០១៤ សន្តិសុខក្រុមហ៊ុនប្រមាណជា៤០នាក់ និងទាហានឆ័ត្រយោង៩១១ ព្រមទាំងមន្ត្រីបរិស្ថាន បានឈូសឆាយដីស្រែ និងដុតផ្ទះប្រជាពលរដ្ឋចំនួន ៣៥គ្រួសារ ដែលរស់នៅទីនោះ។ ពួកគេ

បានហាមឃាត់ប្រជាពលរដ្ឋមិនឲ្យចេញចូលតំបន់នោះថែមទៀតផង។ ប៉ុន្តែករណីវិវាទនេះ បានធ្វើអន្តរាគមន៍ពីទីស្តីការគណៈរដ្ឋមន្ត្រី បន្ទាប់ពីប្រជាពលរដ្ឋរងផលប៉ះពាល់បានប្រមូលផ្តុំធ្វើការបិទផ្លូវអស់រយៈពេលបីយប់បីថ្ងៃ។ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញ ស.ជ.ណ លេខ៣១៥ ចុះថ្ងៃទី១៩ កម្ភៈ ឆ្នាំ២០១៤ ដើម្បីផ្អាករាល់សកម្មភាពរបស់ក្រុមហ៊ុន និងរងចាំរហូតដល់មានដំណោះស្រាយ។ ទោះជាមានចេញនូវ ស.ជ.ណ នេះក្តី ក្រុមហ៊ុនចិនមួយនេះ នៅតែបន្តប្រើប្រាស់គ្រឿងចក្រ (ប៊ូលដូឌើរ) ដើម្បីឈូសឆាយដីស្រែដែលជារបស់ប្រជាពលរដ្ឋចំនួន ៥០ហិចតា ដែលមានទីតាំងនៅក្នុងភូមិព្រែកស្វាយ ព្រែកតាតែន និងភូមិតានូន ឃុំតានូន ស្រុកបុទុមសាគរ ខេត្តកោះកុង។

លើសពីនេះទៅទៀត នៅថ្ងៃទី១០ និង១១ ខែវិច្ឆិកា ឆ្នាំ២០១៤ សន្តិសុខរបស់ក្រុមហ៊ុន៤០នាក់ បានបំផ្លាញ និងដុតផ្ទះ១៨ខ្នង នៅក្នុងភូមិកៀនក្រឡាញ់ ក្រោយការបំផ្លាញនេះ ដែលធ្វើឲ្យប្រជាពលរដ្ឋរងគ្រោះចំនួន ១៨គ្រួសារ ទៅស្នាក់នៅក្នុងវត្ត។ សកម្មភាពឈូសឆាយដីធ្លីរបស់ប្រជាពលរដ្ឋនៅតែបន្តរហូតដល់ថ្ងៃ៣០ ខែតុលា ឆ្នាំ២០១៥។ យ៉ាងណាមិញ វិវាទនេះ បានដោះស្រាយមួយផ្នែកបន្ទាប់ពីប្រជាពលរដ្ឋរងគ្រោះ ប្រមូលផ្តុំគ្នាតវ៉ាជាច្រើនលើកច្រើនសារ និងបានដាក់ពាក្យបណ្តឹងទៅកាន់ស្ថានប័ននានា ដូចជា អាជ្ញាធរខេត្ត រដ្ឋមន្ត្រីក្រសួងបរិស្ថាន គណៈកម្មការទី១នៃរដ្ឋសភា ព្រឹទ្ធសភា ទីស្តីការគណៈរដ្ឋមន្ត្រី ស្ថានទូតប្រទេសចិនប្រចាំនៅកម្ពុជា និង អង្គការសង្គមស៊ីវិល។ ជាលទ្ធផល មានគ្រួសាររងផលប៉ះពាល់ចំនួន ៣១៨គ្រួសារ បានព្រមព្រៀង ផ្លាស់ប្តូរទៅរស់នៅក្នុងទីតាំងថ្មីដែលបានសន្យាថានឹងមានការផ្គត់ផ្គង់សេវាសាធារណៈនៅទីនោះ។

សកម្មភាពនៃការរារាំងផ្លូវចេញចូលទៅក្រុមហ៊ុន UDG ដើម្បីទាមទារឲ្យមានដំណោះស្រាយ

ថតដោយ លោក វង្ស កុសល់

កាលបរិច្ឆេទ: ០៥ និង ០៦ ខែកម្ភ: ឆ្នាំ២០១៤

ប្រភេទដី	#វិវាទដីធ្លីដែលធ្វើបច្ចុប្បន្នភាព ក្នុងឆ្នាំ ២០១៥	ទំហំដី (ហិចតា)	ភាគរយ (%)
ដីកសិកម្ម	១១៣	៥៥.០២៣,៤	៦
ដីរដ្ឋ (រួមទាំងសហគមន៍ព្រៃឈើ)	៥៥	២៤.៥៤៦,៣	២
ដីប្រើប្រាស់សម្រាប់គោលបំណងច្រើនយ៉ាង	៧២	១២៣.២៨១,០	១២
ដីភូមិ/ដីលំនៅឋាន	៦១	៧៩១.០៣៥,៩	៧៩
ផ្សេងៗ	៣	៣២៥,០	០

មិនដឹង	៤	៨០៦,០	០
សរុប	**៣០៨**	**៩៩៥.០១៧,៦**	**១០០**

តារាងទី ១២: ប្រភេទដីដែលរងផលប៉ះពាល់ពីដីមានទំនាស់

៥.៧ មូលហេតុនៃទំនាស់ដីធ្លី

ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺជាមូលហេតុធំបំផុតនៃវិវាទដីធ្លីនៅកម្ពុជា។ គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចចំនួន ៩៧ក្រុមហ៊ុន បានកំពុងបង្ករឲ្យមានវិវាទដីធ្លីនៅក្នុងខេត្ត ចំនួន១៨ ដោយវិវាទដីធ្លីចំនួន ៤២ករណី ត្រូវបានប្រើប្រាស់អំណាចក្នុងការរំលោភយកដី វិវាទដីធ្លីចំនួន ៣០ករណី មានប្រើអំពើហឹង្សា វិវាទដីធ្លី ២២ករណី មានជាប់ពាក់ព័ន្ធជាមួយអាជ្ញាធរ ហើយវិវាទដីធ្លីចំនួន ២០ករណី មានការចាប់ខ្លួនប្រជាពលរដ្ឋ។ ឧទាហរណ៍ ករណីវិវាទលេខ២៧៤៦ ប្រជាពលរដ្ឋចំនួន ១១ នាក់ ត្រូវបានចោទប្រកាន់ដោយអាជ្ញាធរពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន ក្នុងនោះប្រជាពលរដ្ឋម្នាក់ត្រូវបានចាប់ឃុំខ្លួន និងក្រោយមកត្រូវបានគេដោះលែងវិញ នៅក្នុងវិវាទដីធ្លីដែលកើតឡើងរវាងក្រុមហ៊ុនទ្រីភាព ជាមួយប្រជាពលរដ្ឋចំនួន ១០០ គ្រួសារ ដែលភាគច្រើនជាជនជាតិដើមភាគតិចនៅភូមិអូរពោធិ៍ ឃុំរមណីយ ស្រុករវៀង ខេត្តព្រះវិហារ។

ករណីផ្សេងទៀត នៅក្នុងវិវាទលេខ២៧៥០ នៅឃុំព្រះមេ ស្រុកឆែប ខេត្តព្រះវិហា មានប្រជាពលរដ្ឋចំនួន ១២នាក់ជាជនជាតិដើមភាគតិច រងគ្រោះដោយការប្រើប្រាស់អំពើហឹង្សារ និងត្រូវបានប្តឹងដោយអាជ្ញាធរមូលដ្ឋានពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន (ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន) ក្នុងនោះសកម្មជនដីធ្លីចំនួន ០២ នាក់ ត្រូវបានចាប់ឃុំខ្លួនបន្ទាប់ពីការប្រមូលផ្តុំតវ៉ានៅក្នុងវិវាទដីធ្លីរវាងក្រុមហ៊ុនរ៉ៃយហ្វេង ជាមួយប្រជាពលរដ្ឋ ចំនួន ៩៥គ្រួសារ ស្មើរនឹង២៨៧នាក់។ លើសពីនេះទៅទៀត នៅក្នុងឆ្នាំ២០១៤ ប្រជាពលរដ្ឋត្រូវបានបណ្តេញចេញពីលំនៅឋាន ដែលបង្ករឲ្យ ករណីវិវាទនៅតែបន្តរ និងក្រោយក៏មានអន្តរាគមន៍ពីអង្គការសង្គមស៊ីវិល អាជ្ញាធរ ឃុំ/ស្រុក ខណ្ឌរដ្ឋបាលព្រៃឈើ។

១០នាក់ត្រូវចូលបំភ្លឺតុលាការព្រះវិប

ធាក់ សិងលី

ព្រះវិហារ : សហគមន៍ជនជាតិដើមភាគតិច និងមន្ត្រីអាជ្ញាធរក្នុងស្រុកត្បែងមានជ័យជាង១០នាក់ បាននិងកំពុងចូលបំភ្លឺនៅតុលាការខេត្តព្រះវិហារ ពាក់ព័ន្ធទៅនឹងរឿងជម្លោះដីធ្លីជាមួយនឹងក្រុមហ៊ុនចិនឡានហ្វេង រ៉ុយហ្វេង និងបុគ្គលឯកជនម្នាក់។

ក្រុមហ៊ុនចិននេះបានប្តឹងស្ត្រីសហគមន៍ជនជាតិដើមភាគតិចកួយ ឈ្មោះ រឿង ខាន់ អាយុ៥០ឆ្នាំ ឈ្មោះ ស៊ុង សាំង អាយុ៥០ឆ្នាំ ឈ្មោះ នួន ម៉ុន អាយុ៦៣ឆ្នាំ និងបុគ្គលិកអង្គការពន្លកខ្មែរ លោក លូត សាំង អាយុ២៨ឆ្នាំពីបទបំផ្លាញទ្រព្យសមត្តិ (ដកអំពៅ) កាលពីខែ

អ្នកភូមិមកតាំទ្រតំណាងដែលចូលបំភ្លឺតុលាការព្រះវិហារ។ រូបសហការី

បំភ្លឺកាលពីចុងខែមុន ដោយបានបដិសេធការចោទប្រកាន់ លើស្រូវពង្រោះគាត់។ ពួកគាត់បានពឹងពាក់មេធាវីមកពីមជ្ឈ-

> អ្នកភូមិមកតាំទ្រតំណាងរបស់ពួកកែដែលត្រូវបានសាលាដំបូងហៅមកសាក់សួរ
>
> ប្រភព៖ ភ្នំពេញប៉ុស្ត៍ ២៦ សីហា ឆ្នាំ ២០១៥

មូលហេតុនៃវិវាទដីធ្លី	#វិវាទដីធ្លី	#ខេត្ត
សម្បទាន	១	១
សម្បទានដីសេដ្ឋកិច្ច	៩៧	១៨
បម្រើគោលដៅយោធា	១៦	៧
សម្បទានរុករ៉ែ	២	២
តម្រូវការដីសម្រាប់ដាំដុះ/កសិកម្ម	៤៣	១៩
ការវិនិយោគរបស់ក្រុមហ៊ុនឯកជន	១៥	៧
មត្រូវការដីសម្រាប់លំនៅឋាន	២៨	១១
សម្បទានដីសង្គមកិច្ច	៩	៦

តំបន់អភិវឌ្ឍន៍របស់រដ្ឋ	២១	៩
ដីរដ្ឋ	៥៨	២០
មិនដឹង	១៨	៤
សរុប	**៣០៨**	

តារាងទី ១៣: មូលហេតុនៃវិវាទដីធ្លី

ប្រភេទ	ករណីវិវាទដីធ្លីនាំឲ្យមានការចាប់ជនរងគ្រោះ	ករណីវិវាទដីធ្លីប្រើប្រាស់អំណាចលើភាគីវិវាទ	ករណីវិវាទដីធ្លីប្រើប្រាស់ការគំរាមកំហែងលើភាគីវិវាទ	ករណីវិវាទដីធ្លីប្រើប្រាស់អំពើរហឹង្សាលើភាគីវិវាទ	ករណីវិវាទដីធ្លីដែលមានជាប់ពាក់ព័ន្ធនឹងអាជ្ញាធរ
#ករណីវិវាទ	៤៧	១៥៦	៨៤	៥៦	៩៦
#ករណីវិវាទពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច	២០	៤២	៣០	២០	២២
#ករណីវិវាទពាក់ព័ន្ធនឹងសម្បទាន	០	១	១	០	១
#ករណីវិវាទពាក់ព័ន្ធនឹងគោលការណ៍បំរើលើវិស័យយោធា	១	១១	៦	៥	៥
#ករណីវិវាទពាក់ព័ន្ធនឹងតម្រូវការដីសម្រាប់ដាំដុះ/កសិកម្ម	៤	១៩	១៣	២	១៨

#ករណីវិវាទពាក់ព័ន្ធនឹងមត្រូវការដីសម្រាប់លំនៅឋាន	៥	១១	១០	១	៨
#ករណីវិវាទពាក់ព័ន្ធនឹងសម្បទានដីសង្គមកិច្ច	២	៧	១	០	៤
#ករណីវិវាទពាក់ព័ន្ធនឹងដីរដ្ឋ	៦	៣៥	១១	១	២២
#ករណីវិវាទពាក់ព័ន្ធនឹងតំបន់អភិវឌ្ឍន៍របស់រដ្ឋ	៣	៦	៦	៥	៤
#ករណីវិវាទពាក់ព័ន្ធនឹងការវិនិយោគរបស់ក្រុមហ៊ុនឯកជន	៥	១១	៦	៥	៦
ផ្សេងៗ	១	១៣	០	១៧	៦

តារាងទី ១៤: វិធីសារនៃការកាន់កាប់ដី

ជាមួយគ្នានេះដែរ ដីរដ្ឋ រួមមាន ដីឯកជនរបស់រដ្ឋ និងដីសាធារណៈរបស់រដ្ឋ ក៏ជាកម្មវត្ថុនៃវិវាទដីធ្លីផងដែរ ខណៈដែលយន្តការនៃការគ្រប់គ្រងដីរដ្ឋមិនទាន់មានប្រសិទ្ធភាពពេញលេញ ហើយដំណើការនៃការចុះបញ្ជីដីរដ្ឋមិនទាន់ចប់នៅឡើយ។ ដីរដ្ឋ មានវិវាទកើតឡើងជាញឹកញាប់ តាមរយៈការទាមទារកម្មសិទ្ធិក្នុងការគ្រប់គ្រង។

ជាក់ស្តែង វិវាទដីធ្លីចំនួន ៦៥ករណី កើតឡើងនៅលើដីព្រៃ ដីព្រៃសហគមន៍ តំបន់ដីព្រៃលិចទឹក ដីរួមរបស់ភូមិ ដីសាលារៀន ដីច្រាំងទន្លេ ដីកប់ខ្មោច ដីឆ្នេរ និងស្រះទឹកសាធារណៈជាដើម។ វិវាទដែលកើតឡើងលើដីរដ្ឋ ភាគច្រើនបង្ករដោយអ្នកមានអំណាចដែលមានតួនាទីខ្ពស់ៗនៅក្នុងស្ថាប័ននានា ឬជាអ្នកមាន ដែលមានទំនាក់ទំនងជាមួយមន្ត្រីមានឋានៈធំៗនៃរដ្ឋាភិបាលកម្ពុជា។ ដូចបានបង្ហាញនៅក្នុងតារាងទី ៩ មានវិវាទដីធ្លីចំនួន ២២ករណី កើតឡើងលើដីរដ្ឋ ហើយវិវាទនេះ មានជាប់ពាក់ព័ន្ធទៅនឹងអាជ្ញាធរដែនដី។ វិវាទដីធ្លីចំនួន ១១ករណី មានការគំរាមកំហែងដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ និង០១ករណីទៀត មានការប្រើប្រាស់អំពើហឹង្សា។ ឧទាហរណ៍ វិវាទដីធ្លីលេខ២៧៩៤ នៅក្នុងភូមិពងទឹក ឃុំខ្នាឆ្មារ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង គឺជាវិវាទដីធ្លីដែលកើតឡើងលើដីរដ្ឋ រវាងប្រជាពលរដ្ឋចំនួន ៣៥០គ្រួសារ (១៣៥៩នាក់) ជាមួយនឹងក្រុមហ៊ុន កុល សារឿន ដែលក្រុមហ៊ុននេះព្យាយាមទិញដីទំហំ ៧២ហិចតា ពីអាជ្ញាធរមូលដ្ឋាន លើដីព្រៃរួមរបស់ភូមិប្រើប្រាស់ក្នុងការប្រមូលអនុផលព្រៃឈើ។ ប្រជាពលរដ្ឋចំនួន ៣៣៨គ្រួសារ ក្នុងចំណោមប្រជាពលរដ្ឋ ៣៥០គ្រួសារខាងលើបានព្រមព្រៀងលក់ដី បន្ទាប់ពីបានចូលរួមប្រជុំពិគ្រោះយោបល់ដែលសម្របសម្រួលដោយក្រុមប្រឹក្សាឃុំ ដែលមានការចូលរួមពីប្រធានភូមិ និងតំណាងក្រុមហ៊ុន។ នៅក្នុងកិច្ចព្រមព្រៀងនោះ ភាគីក្រុមហ៊ុននឹងប្រគល់ប្រាក់ជូនប្រជាពលរដ្ឋក្នុងមួយគ្រួសារចំនួន ២០០ដុល្លាអាមេរិក ប៉ុន្តែគ្រួសារមួយចំនួន ទទួលប្រាក់ជាក់ស្តែងតែ១០០ដុល្លាអាមេរិកប៉ុណ្ណោះ។ ការលក់ដូរនេះមានការជំទាស់ពីប្រជាពលផ្សេងទៀតនៅក្នុងភូមិ និងប្រជាពលរដ្ឋនៅក្នុងភូមិជាប់គ្នានោះ។ ករណីវិវាទនេះក៏មានការចុះអង្កេតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីខែមិថុនា ឆ្នាំ២០១៥ ដោយសារតែវិវាទត្រូវបានចុះផ្សាយតាមសារព័ត៌មាន ជាហូរហែរ និងដឹងដល់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល។ បច្ចុប្បន្នអាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងភាគីក្រុមហ៊ុនកំពុងរងចាំលទ្ធផលនៃការចុះអង្កេត។

ជី72ហិកតាជាជីរដ្ឋ ប្រជាជនខ្លះលក់ឱ្យឈ្មួញ
ខ្លះទៀតមិនព្រមលក់ផ្ទុះការប្តឹងប្តូលទៅសាលាខេត្ត

ខេត្តកំពង់ឆ្នាំង ៖ ដីចំនួន៧២ហិកតា នៅចំណោចព្រៃគីឡូ ស្ថិតក្នុងភូមិត្រដក់ពង ឃុំខ្នារឆ្មារ ស្រុកសាមគ្គីមានជ័យ ជាដីសម្បូរភាពភូមិ ត្រូវបានឈ្មួញចូលនាប្រជាពលរដ្ឋក្នុងភូមិនេះលក់ទៅឱ្យខ្លួន ដែលក្នុងមួយគ្រួសារទទួលបាន២០០ដុល្លារ ។

ភនេវនំភាំ 5

ភនេវនំភាំ 1

ប៉ុន្តែក្រោយពេលទទួលប្រាក់ពីឈ្មួញរួចស៊ីដីរួចហើយ ស្រាប់តែមានប្រជាពលរដ្ឋជាង៦០គ្រួសារទៀត ដែលរស់ស្រុះស្រួលនឹងមធ្យោបាយរកស៊ីដីនោះ ចុកជាប្រយោជន៍ភូមិទៅថ្ងៃមុខ ចេញមុខប្តឹងមកដែលប្តឹងជំទាស់ជាក់ជួនទៅលោកអភិបាលខេត្តសំណូមពរឱ្យកាន់ដីនោះ ចុកជាសម្បត្តិសាធារណៈទៅថ្ងៃអនាគត ។ ក្រើយ៉ាងដឹងច្រើនក្រសេះនេះ បានអូសបន្លាយជិត២ខែមកហើយដោយសារការចិញ្ចឹលការប្រជាពលរដ្ឋ និងឈ្មួញក្រវាបានមើលឃើញថាមិនស្របតាមច្បាប់អ្វីទាំងអស់ ហើយប្រជាពលរដ្ឋមួយចំនួនហាក់ភ្ញាក់ខ្លួនក្រោយពីទទួលលុយចំនួន២០០ដុល្លារ ។

លោកឆាង សុខ ជំទប់ទី១ឃុំខ្នារឆ្មារបានឱ្យដឹងថា ជាយូរណាស់មកហើយមានក្រុមអ្នករកស៊ីដីធ្លីមកទិញដីពីប្រជាពលរដ្ឋក្នុងភូមិត្រដក់ពង ក្នុងតម្លៃ ២០០ដុល្លារក្នុងមួយគ្រួសារ ដោយមិនបានប្រាប់ពីគោលបំណងច្បាស់លាស់ថាយកទៅធ្វើអ្វីនោះទេ ។ ប៉ុន្តែក្រោយមកទើបដឹងថាគេយកទៅធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយមិនបានប្រាប់ប្រជាពលរដ្ឋឱ្យបានដឹងជាមុនសោះ ។ ដោយឃើញដូច្នេះ ប្រជាពលរដ្ឋក៏បានប្តឹងប្តូលទៅអាជ្ញាធរមូលដ្ឋានជាច្រើនលើកច្រើនសារ ប៉ុន្តែមិនទាន់ទទួលបានដំណោះស្រាយនៅឡើយ ។

ប្រភពដដែលបន្តថា ស្រាប់តែព្រឹកថ្ងៃទី១៤ ធ្នូ ២០១៣ លោក កុល សារឿន ដែលជាឈ្មួញចិញ្ចឹដីបានបើកប្រាក់ឱ្យប្រជាពលរដ្ឋក្នុងមួយគ្រួសារចំនួន២០០ដុល្លារ ដោយឱ្យប្រជាពលរដ្ឋផ្តិតមេដៃទទួលយកលុយជាបន្ទាប់ រហូតដល់ជាង៣០០គ្រួសារដែលបានទទួលលុយ សព្វថ្ងៃនៅសល់តែ២០ទៅ៣០គ្រួសារប៉ុណ្ណោះ ដែលមិនទាន់បានទទួលយកលុយ ។ ប៉ុន្តែក្នុងនោះផងដែរ អ្នកបានទទួលលុយខ្លះពីបានតែ១០០ដុល្លារដោយអ្នកចិញ្ចឹនៅជាក់លិន ឱ្យខ្លះទៀតជាសន្យាថាក៏មានដែរ ។

លោក ថា កុំ មេឃុំខ្នារឆ្មារថ្លែងថា នៅរសៀលថ្ងៃទី១៣ ធ្នូ ឆ្នាំ២០១៣ ពិតជាបានប្រជុំក្រុមប្រឹក្សាឃុំនៅសាលាឃុំមែន ហើយបានឯកភាពលើសិន ។

ក្រុមអ្នកភូមិដែលតវ៉ានឹងជំទាស់ការលក់ដីរួម (ប្រភព សុខហ៊ាន)

ប្រជាពលរដ្ឋដែលជំទាស់នឹងការលក់ដីព្រៃរិចរិលដែលជាដីរួមរបស់ភូមិ

រូបថត: ការសែតកោះសន្តិភាព ១៥ ១៦ ខែកម្ភៈ ឆ្នាំ២០១៥

ករណីវិវាទដីធ្លីមួយផ្សេងទៀត (លេខ ២២៣០) នៅក្នុងខេត្តកំពង់ស្ពឺ ក្រុមប្រឹក្សាឃុំនិងមេភូមិ ត្រូវបានចោទប្រកាន់ពីបទលក់ដូរដីនៅលើចង្កេះភ្នំ ទំហំ ២៥,៤៧ហិចតា ទៅឲ្យក្រុមហ៊ុនម៉ុងរដ្ឋា ដែលធ្វើការវិនិយោគលើការដាំល្អុងខ្វង និងសណ្តែកប្រេង។ ករណីវិវាទនេះមិនទាន់បានដោះស្រាយនៅឡើយ។

ដោយឡែក វិវាទដីធ្លីនៅតាមមាត់ស្ទឹងពោធិ៍សាត់ (លេខ ២៨១៥) នៅក្នុងភូមិក្បាលហុង និងភូមិពោធិ៍កំបោរ ឃុំវាល ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ មានប្រជាពលរដ្ឋ ៦០គ្រួសារ រស់នៅលើចំណីផ្លូវនិងក្បែរចំណីស្ទឹង គឺសាលាខេត្តបានចេញលិខិតជូនដំណឹងនៅថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៤ ឲ្យប្រជាពលរដ្ឋរើចេញ ក្នុងគោលបំណងរៀបចំសណ្តាប់ធ្នាប់សាធារណៈ។ ដោយសារតែមានការប្រឆាំង និងការតវ៉ា

របស់ប្រជាពលរដ្ឋរងគ្រោះ ទើបនៅក្នុងខែមិថុនា ឆ្នាំ២០១៥ អជ្ញាធរខេត្ត បានឯកភាពផ្តល់សំណងជូនប្រជាពលរដ្ឋ ៤គ្រួសារ ដោយផ្អែកលើគុណភាពនៃសំណង់។ សំរាប់ប្រជាពលរដ្ឋរងគ្រោះផ្សេងទៀត គឺស្ថិតនៅក្នុងដំណើរការនៃការដោះស្រាយ។

៥.៨ ឯកសារ និង ភិធីសាស្ត្រដែលប្រើប្រាស់ដោយភាគីចំពីរក្នុងការឆ្លងបានដី

យោងតាមលទ្ធផល ភាគីវិវាទស្វែងរកនូវមធ្យោបាយខុសៗគ្នា ក្នុងការទាមទារយកដីទំនាស់[17]។ ករណីវិវាទដីធ្លីចំនួន ១១៩ករណី ក្នុងចំណោម ៣០៨ករណី បានរាយការណ៍ថា ភាគីវិវាទប្រើប្រាស់ឯកសារគាំទ្រ ឬលិខិតអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ក្នុងការទាមទារយកដី។ ក្នុងករណីខ្លះ មានការលើកឡើងថា ឯកសារមួយចំនួនទទួលបានដោយមិនត្រឹមត្រូវ ជាឧទាហរណ៍ ករណី វិវាទលេខ២៥៥១ ជាវិវាទដីធ្លីក្នុងភូមិចាន់ក្រី ឃុំជបរាី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ មានប្រជាពលរដ្ឋ៣២គ្រួសារ មករស់នៅក្នុងភូមិនេះតាំងពីឆ្នាំ១៩៨៧។ ពួកគេមួយចំនួនទទួលបានប័ណ្ណកម្មសិទ្ធដីធ្លី និងមួយចំនួនទៀតកំពុងដំណើរការចុះបញ្ជីដី ប៉ុន្តែនៅក្នុងឆ្នាំ២០១១ ក្រុមទាហានកាំភ្លើងធំ បានមកបោះទីតាំងនៅលើដីស្រែ ដីចំការ និងដីលំនៅឋានរបស់ប្រជាពលរដ្ឋទាំងនោះ។ ប្រជាពលរដ្ឋ ត្រូវបានហាមឃាតមិនឲ្យចូលទៅទីតាំងដែលក្រុមទាហានរំលោភយកដីទាំងនោះទេ សកម្មភាពរបស់ក្រុមទាហានកាំភ្លើងធំបានធ្វើឡើង ដោយសំអាងលើលិខិតអនុញ្ញាតិពីអភិបាលខេត្ត។ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ តំបន់វិវាទ បានដាក់បញ្ចូលទៅក្នុងតំបន់វិនិច្ឆ័យនៃដំណើរការចុះបញ្ជីជាលក្ខណៈប្រព័ន្ធ តាមរយៈដំណើរការនេះ បានរកឃើញថា មានប្រជាពលរដ្ឋ ១៧០គ្រួសារ ស្មើរនឹង២៥៥ក្បាលដី (រួមទាំងផ្ទះ៤៣ខ្នង) ត្រូវរងផលប៉ះពាល់នៃការបោះទីតាំងទ័ព។ តំណាងទាហានកាំភ្លើងធំ ជំទាស់ទៅនឹងការចុះបញ្ជីនេះ ហើយទាមទារផ្ទៃដីចំនួន ៣៣ហិចតា សំរាប់ការរៀបចំបន្ទាយទាហាន ដោយមិនបាន

[17] ចំពោះគោលបំណងនៃរបាយការណ៍នេះ គឺវិវាទសំដៅដល់បុគ្គលដែលទាមទារដីពីម្ចាស់ដើម ។

បញ្ហាក់ទីតាំងច្បាស់លាស់ឡើយ។ ឆ្លើយតបនឹងការងារនេះ អភិបាលខេត្ត បានដឹកនាំកិច្ចប្រជុំមួយកាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៤ ហើយបានស្នើសុំឲ្យភាគីទាហានកាំភ្លើងធំ ប្តូរទីតាំងបន្ទាយទាហានទៅក្នុងបន្ទាយទាហានភូមិភាគទី៥១។ ប៉ុន្តែតំណាងទាហានកាំភ្លើងធំ បានច្រានចោលការស្នើរសុំនេះ និងរងចាំពិក្សាពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំ។ បច្ចុប្បន្ននេះ ករណីវិវាទមួយនេះកំពុងរងចាំដំណោះស្រាយ ។

ខាងក្រោមនេះជាវិធិសាស្ត្រ និងមធ្យោបាយដែលគូរភាគីវិវាទប្រើប្រាស់ជាសំអាងក្នុងការទាមទារដី៖

- ការគំរាមកំហែងប្រឆាំងនឹងអ្នកកាន់កាប់ដីដើម/ភាគីវិវាទ
- អំពើហិង្សាប្រឆាំងនឹងអ្នកកាន់កាប់ដីដើម/ភាគីវិវាទ
- ការចាប់ឃុំខ្លួនអ្នកកាន់កាប់ដីដើម/ភាគីវិវាទ
- ការបំពាន់ដោយប្រើអំណាចរបស់មន្ត្រីរដ្ឋាភិបាល និងអ្នកដែលមានទំនាក់ទំនងល្អជាមួយអ្នកជំនួញធំៗ
- លិខិតអនុញ្ញាតពីអាជ្ញាធរ



រូបទី ៦:យុទ្ធសាស្ត្រក្នុងការទទួលបានដី

ម្យ៉ាងទៀត ភាគីវិវាទក៏បានប្រើប្រាស់នូវឯកសារផ្សេងៗគ្នា ក្នុងការទាមទារកាន់កាប់ដី ឬដើម្បីក្លាយជាម្ចាស់កម្មសិទ្ធិដី។ វិវាទដីធ្លីចំនួន ៩៧ករណី ជាប់ពាក់ព័ន្ធនឹងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ហើយដែលភាគីខាងក្រុមហ៊ុនបានប្រើប្រាស់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចក្នុងការទាមទារដីធ្លីប្រឆាំងនឹងប្រជាពលរដ្ឋ បើទោះដឹងថាប្រជាពលរដ្ឋទាំងនោះ បានមករស់នៅទីនោះមុនការផ្តល់សម្បទានដីសេដ្ឋកិច្ចក៏ដោយ។ ដូចគ្នានេះដែរ កិច្ចសន្យារុករករ៉ែចំនួនពីរ ត្រូវបានប្រើប្រាស់ក្នុងការទាមទារដីពីប្រជាពលរដ្ឋ។ វិវាទដីធ្លី ៥ករណីទៀត បានប្រើប្រាស់កិច្ចសន្យានៃការផ្តល់

សម្បទានដីសង្គមកិច្ច ក្នុងការទាមទារកាន់កាប់ដី ឬជាកម្មសិទ្ធិករ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ដែលមានវិវាទជាមួយនឹងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ឬជាមួយនឹងភាគីវិវាទផ្សេងៗទៀត មិនមានឯកសារសំអាងក្នុងការទាមទារយកដីរបស់ពួកគេទេ ដោយសារការផ្តល់កម្មសិទ្ធិដីធ្លី ឬការចុះបញ្ជីដីសម្បហាភាពរបស់ជនជាតិដើមភាគតិច មិនទាន់បានអនុវត្តនៅក្នុងតំបន់របស់ពួកគេនៅឡើយ។ មានវិវាទចំនួន ២៩ករណី ប្រជាពលរដ្ឋជនជាតិដើមភាគតិច ប្រើប្រាស់សិទ្ធិប្រពៃណីរបស់ជនជាតិដើមភាគតិចក្នុងការប្រឆាំងតវ៉ាជាមួយភាគីវិវាទ។

ឯកសារប្រើប្រាស់ក្នុងការទាមទារក្នុងការកាន់កាប់ដី	#វិវាទដីធ្លី
សិទ្ធប្រពៃណីជនជាតិដើមភាគតិច	២៩
ឯកសារសម្បទានដីសេដ្ឋកិច្ច	១០៤
ឯកសារសម្បទានរុករករ៉ែ	២
លិខិតដែលទទួលស្គាល់ពីអាជ្ញាធរ	៥៥
លិខិតកាន់កាប់ដីដែលចេញដោយអាជ្ញាធរនៅចុងទសវត្សរ៍ឆ្នាំ១៩៨០	៧
កិច្ចសន្យាសម្បទានដីសង្គមកិច្ច	៥
ប័ណ្ណកម្មសិទ្ធិ	២១
កិច្ចសន្យាលក់/ទិញឯកជន	៤៣
ផ្សេងៗ	១២៨

តារាងទី១៥: ឯកសារប្រើប្រាស់សំរាប់ទាមទារក្នុងការកាន់កាប់ដី ឬជាម្ចាស់កម្មសិទ្ធិ

ក្រៅពីនេះ មានឯកសារលក់ទិញឯកជន ចំនួន ៤៣ករណី សំដៅដល់សំបុត្រនៃការទិញលក់ ដែលពេលខ្លះមានការចុះហត្ថលេខាមេភូមិ ឬមេឃុំ ត្រូវបានប្រើប្រាស់ក្នុងការទាមទារកាន់កាប់ដី ឬជាកម្មសិទ្ធិករ។ វិវាទចំនួន ៧ករណី មានលិខិតបញ្ជាក់ការកាន់កាប់ដី ដែលចេញដោយអាជ្ញាធរនៅក្នុងឆ្នាំ១៩៨០ ត្រូវបានប្រើប្រាស់

ក្នុងការទាមទារកាន់កាន់ដី ឬជាកម្មសិទ្ធិករផងដែរ។ ឯកសារផ្សេងៗ ដូចជា ផែនទីគំរបព្រៃឈើឆ្នាំ២០០២ ឯកសារដីធ្លីដែលផ្តល់ជូនគ្រួសារទាហានចូលនិវត្តន៍ ឯកសារបន្ទាយទាហានចាស់ៗ ពាក្យស្នើសុំកាន់កាប់ដីធ្លីជាដើម បានប្រើប្រាស់ជាឯកសារក្នុងការទាមទារ ឬជាឯកសាសំអាងនៃការកាន់កាប់ដី សរុបចំនួន ១២៨ករណី។

៦. ការកាន់កាប់បច្ចុប្បន្នលើដីមានទំនាស់

ស្ថានភាពនៃការកាន់កាប់ ឬការគ្រប់គ្រងដី នៅពេលដែលទំនាស់មានលក្ខណៈខុសគ្នា ពីករណីមួយទៅករណីមួយ។ វិវាទដីធ្លីចំនួន ៩២ករណីស្មើរនឹង៣២ភាគរយនៃករណីដែលកំពុងកើតមាននិងរងចាំការដោះស្រាយ ត្រូវបានកាន់កាប់ដោយអ្នកកាន់កាប់ដីដើម។ ៨៣ករណីស្មើរនឹង២៩ភាគរយ កាន់កាប់ដោយភាគីទីពីរនៃវិវាទ និងវិវាទចំនួន ៦១ករណីស្មើរ២១ភាគរយ កំពុងកាន់កាប់ដីដោយភាគីទាំងសងខាង ហើយវិវាទចំនួន ៥០ករណីស្មើរនឹង១៧ភាគរយ មិនបានដឹងពីស្ថានភាពនៃការកាន់កាប់។

មានវិវាទចំនួន ៩៧ករណី ដែលបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច កំពុងបន្ត និងរងចាំដំណោះស្រាយ ក្នុងនោះវិវាទ២៩ ត្រូវបានកាន់កាប់ដោយភាគីចុងបណ្តឹងជា"ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច" មានទំហំដី ៥៦,០៣៥.០០ហិចតា ប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៥,១៩៥.០០គ្រួសារ [18]។ ភាគច្រើននៃករណីវិវាទដីធ្លីទាំងនោះ ជាដីកសិកម្មដែលជាប្រភពចំណូលចំបងរបស់ប្រជាពលរដ្ឋ។ ដូច្នេះជីវភាពប្រជាពលរដ្ឋរងផលប៉ះពាល់ត្រូវបានប្រឈមនឹងបញ្ហាជាច្រើន។ ជាមួយគ្នានេះដែរ វិវាទចំនួន ២៦ករណី ត្រូវបានកាន់កាប់ដោយអ្នកកាន់កាប់ដើម ដែលជា "

[18] ករណីទាំង ២៩ កើតមានក្នុងខេត្ត បាត់ដំបងចំនួន១ករណី, ខេត្តកំពង់ស្ពឺ ៤ករណី, ខេត្តកមបង់ធំ២ករណី, ខេត្តកោះកុង១ករណី, ខេត្តមណ្ឌលគិរី៤ករណី, ខេត្តឧត្តរមានជ័យ១ករណី, ខេត្តពោធិ៍សាត៣ករណី, ខេត្តរតនគិរី៨ករណី, ខេត្តព្រះសីហនុ១ករណី, ខេត្តស្វាយរៀង២ករណី និងខេត្តត្បូងឃ្មុំ១ករណី

ប្រជាពលរដ្ឋមូលដ្ឋាន"។ វិវាទចំនួន ២៤ករណីកាន់កាប់ដោយភាគីទាំងសងខាងនៃវិវាទ និងវិវាទចំនួន ១២ករណីទៀត មិនមានព័ត៌មានអំពីស្ថានភាពនៃការកាន់កាប់ដីទេ។

ស្ថានភាពការកាន់កាប់ដីធ្លីវិវាទ		
ស្ថានភាពកាន់កាប់ដី	**#វិវាទដីធ្លី**	**ភាគរយ (%)**
ភាគីវិវាទកំពុងកាន់កាប់ដីវិវាទ	៨៣	២៩
ភាគីអ្នកកាន់កាប់ដីដើមកំពុងកាន់កាប់ដីវិវាទ	៩២	៣២
ភាគីវិវាទទាំងសង់ខាងកំពុងកាន់កាប់	៦១	២១
មិនដឹង	៤៩	១៧
សរុប	**២៨៥**	**100**

តារាងទី ១៦: ស្ថានភាពនៃការកាន់កាប់ដីធ្លីនៅលើវិវាទដីធ្លី

៧. ចំនាស់ដីធ្លីដែលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ច

វិវាទដីធ្លីចំនួន ៩៧ករណី ស្មើនឹង៣១.៤៩ ភាគរយនៃករណីវិវាទសរុប បានបង្ករឡើងដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច[19] កើតមាននៅក្នុងខេត្តចំនួន១៨ ស្មើនឹង ៧២ភាគរយនៃខេត្តទូទាំងប្រទេស (ចំនួននេះមិនរាប់បញ្ចូលនូវការផ្តល់ដីសម្បទានសង្គម និងសម្បទានក្នុងគោលបំណងផ្សេងទៀតនោះទេ)។ ករណីវិវាទទាំងនោះភាគច្រើនកើតមាននៅក្នុងខេត្តភាគឦសាននៃប្រទេសកម្ពុជា និងជាតំបន់ដែលជាទូទៅសំរាប់ដាំដំណាំកៅស៊ូ ក្នុងនោះ ១៥ករណីកើតឡើងនៅក្នុងខេត្តរតនគិរី ១៣ករណីនៅខេត្តមណ្ឌលគិរី ហើយ១១ករណីកើតនៅខេត្តកំពង់ស្ពឺនិងព្រះវិហារ ៧ករណីកើតឡើងនៅក្នុងខេត្តកោះកុង ៦ករណីកើតឡើងនៅក្នុងខេត្តពោធិ៍សាត់ ៥ករណីកើតឡើងនៅក្នុងខេត្តក្រចេះ ព្រះសីហានុនិងខេត្តស្វាយរៀង ៤ករណីកើត

[19] ករណីនេះរួមបញ្ចូលទាំងករណីដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងនៅក្នុងឆ្នាំ២០១៥

ឡើងនៅក្នុងខេត្តកំពង់ធំ ៣ករណីកើតឡើងនៅក្នុងខេត្តត្បូងឃ្មុំ ២ករណីកើតឡើងនៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង ឧត្តរមានជ័យ សៀមរាបនិងខេត្តស្វាយរៀង ១ករណីកើតឡើងនៅក្នុងខេត្តកំពតនិងខេត្តកំពង់ចាម។ ជាសរុបមានប្រជាពលរដ្ឋចំនួន ១៩,៧២០.០០គ្រួសារ ស្មើនឹង៣៥,១៥៣.០០នាក់[20] ដែលរងផលប៉ះពាល់ដោយសារវិវាទដីធ្លីដែលពាក់ព័ន្ធនឹងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។

ស្របគ្នានេះដែរ វិវាទដីធ្លីបង្ករដោយសម្បទានដីសេដ្ឋកិច្ចកំពុងប៉ះពាល់ជីវភាពរបស់ប្រជាពលរដ្ឋទូទៅក៏ដូចគ្នានឹងប្រជាពលរដ្ឋជនជាតិដើមភាគតិចយ៉ាងធ្ងន់ធ្ងរ។ ជីវភាពរបស់ពួកគេគឺពឹងផ្អែកទៅលើការធ្វើកសិកម្ម ការប្រមូលជ័រ បោចវ័រ បះផ្លែឈើព្រៃ នេសាទ និងការបរបាញ់ជាលក្ខណៈប្រពៃណីក្នុងការទ្រទ្រង់ជីវភាពគ្រួសារ។ នៅពេលដែលអនុផលព្រៃឈើត្រូវបានបាត់បងទាំងស្រុង ដោយសារតែការឈូសឆាយដីព្រៃ ដីចំការពនេចរ និងដីវាលស្មៅសំរាប់ចិញ្ចឹមសត្វ គឺនាំឲ្យប្រជាជនបាត់បង់ចំណូលទាំងស្រុង។ ប្រឡាយធម្មជាតិ ផ្លូវទឹកធម្មជាតិ បឹងនិងស្រះតូចៗ ជាផ្លូវទឹកធម្មជាតិសំរាប់ហ្វូងត្រីធ្វើដំណើរ រស់នៅ និងបន្តពូជ ហើយក៏ជាប្រភពទឹកសំរាប់ស្រោចស្រពផ្ទៃដីស្រែ និងជាប្រភពទឹកធម្មជាតិមួយសំរាប់ចាក់បំពេញទៅតំបន់ស្តុកទឹកទាបៗសំរាប់ប្រើប្រាស់នៅរដូវប្រាំង ដែលជាធនធានដ៏មានសារសំខាន់សំរាប់ប្រជាពលរដ្ឋមូលដ្ឋាន ត្រូវបានបាត់បង់ដោយសារការឈូសឆាយរបស់ក្រុមហ៊ុន។ ជាងនេះទៅទៀត វិវាទខ្លះក្លាយជាឧបសគ្គចំពោះប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារភាគីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច បានកាន់កាប់ដីរបស់ប្រជាពលរដ្ឋ ហើយបានរារាំង ឬហាមឃាត់ពួកគាត់មិនឲ្យចូលទៅប្រើប្រាស់ដីដែលធ្លាប់អាស្រ័យផល ខណៈដែលវិវាទមិនទាន់បានដោះស្រាយ។

[20] ចំនួននេះជាចំនួនជាក់ស្តែងដែលមានក្នុងមូលដ្ឋានទិន្នន័យអំពីចំនួនប្រជាពលរដ្ឋរងផលប៉ះពាល់ពីវិវាទដីធ្លីដែលបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ប៉ុន្តែមានតែករណីចំនួន ៣៧ប៉ុណ្ណោះដែលបានបង្ហាញអំពីចំនួនប្រជាជនដែលរងផលប៉ះពាល់។ ដូចនេះចំនួនប្រជាជនដែលរងផលប៉ះពាល់អាចមានច្រើនជាងនេះ។

នៅក្នុងករណីធ្ងន់ធ្ងរ ប្រជាពលរដ្ឋរងគ្រោះត្រូវបានចាប់ឃុំខ្លួន រងនូវអំពើហឹង្សា ការគំរាមកំហែង និងត្រូវបានបង្ខំឲ្យចេញពីផ្ទះសំបែង។ ប្រជាពលរដ្ឋរងផលប៉ះពាល់ មានការមមាញឹកជាមួយនឹងការតវ៉ាទៅស្ថាប័នជាច្រើនដើម្បីទាមទារឲ្យមានការដោះស្រាយ។ ពួកគេបានចំណាយធនធានផ្ទាល់ខ្លួនលើការងារតវ៉ានេះ ហើយបានបង្កើនបន្ទុកទៅលើស្ត្រីកាន់តែធ្ងន់ធ្ងរ ប៉ះពាល់ទៅដល់ផ្លូវអារម្មណ៍ ប៉ះពាល់ដល់ជីវភាព សុខភាព និងកូនៗបាត់បង់ភាពកក់ក្តៅ មិនអាចចូលសាលារៀនបាន។

យ៉ាងណាមិញ មានខេត្តចំនួន៧ និងរាជធានីមួយ ក្នុងនោះមានខេត្តកំពង់ឆ្នាំង កណ្តាល កែប ប៉ៃលិន ព្រៃវែង តាកែវ និងរាជធានីភ្នំពេញ មិនមានវិវាទដីធ្លីដែលបង្ករឡើងដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទេនៅក្នុងឆ្នាំ២០១៥។



រូបទី ៨: ចំនួនទំនាស់ដីធ្លីទាក់ទិននឹងសម្បទានដីសេដ្ឋកិច្ច

៨. ទំនាស់ដីធ្លីដែលបង្ករផលប៉ះពាល់លើជនជាតិដើមភាគតិច

ប្រមាណជា១៧.៨ភាគរយ ស្មើនឹង៥១ករណី ក្នុងចំណោមករណីវិវាទដីធ្លី ដែលកំពុងបន្ត ប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច នៅក្នុងខេត្តចំនួន ៩។ វិវាទដីធ្លី ៣៩ករណី ដែលបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ប៉ះពាល់ទៅដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ចំនួន ៦,៨៩៧.០០គ្រួសារ។

ខេត្តរតនគិរី មានករណីវិវាទដីធ្លីប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចច្រើនជាងគេ មានចំនួន ២៣ករណី ស្មើនឹង ២,៤០៥.០០ គ្រួសារ។ វិវាទទាំង ២៣ ករណីនេះមាន១៥ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ៥ករណីជាវិវាទនៅលើដីរដ្ឋ ២ករណីជាវិវាទជាមួយក្រុមហ៊ុនឯកជន និង ១ករណីជាវិវាទលើដីសហគមន៍ជាមួយក្រុមហ៊ុនឯកជន។ បន្ទាប់មកគឺខេត្តមណ្ឌលគិរី មានវិវាទដីធ្លីចំនួន ១៣ ករណីស្មើនឹង ៤,២៩៧.០០គ្រួសារ ក្នុងនោះមាន ១០ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និង ៣ករណីទៀត ជាវិវាទពាក់ព័ន្ធទៅនឹងសម្បទានដីសង្គមកិច្ច និងដីសំរាប់ដាំដុះ។

ក្រៅអំពីផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងសង្គមចំពោះប្រជាពលរដ្ឋដូចបានលើកឡើងខាងលើ វិវាទដីធ្លីបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច បានប៉ះពាល់លើបញ្ហាផ្សេងៗទៀតដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ដូចជា ប៉ះពាល់ដល់ប្រពៃណី ទំនៀមទំលាប់ ព្រៃតំនប ព្រៃកប់ខ្មោច និងព្រៃឈើដែលជាជំរកសត្វព្រៃ និងដើមជ័រទឹកដែលប្រជាពលរដ្ឋធ្លាប់ទាញយកប្រយោជន៍។ ការបាត់បង់ដីវាលស្មៅសំរាប់ចិញ្ចឹមគោក្របី និងតំបន់ដែលមានរុក្ខជាតិប្រើប្រាស់ជាឱសុទ្ធបុរាណជីធម្មជាតិដែលធ្លាប់ហូរពីតំបន់ខ្ពស់ៗទៅតំបន់ដីកសិកម្មទាបៗដែលប្រជាជនមិនចាំបាច់ទិញជីគីមីសំរាប់ដាំដំណាំ។



រូបទី ៩: ទីកន្លែងរបស់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ពីទំនាស់ដីធ្លី

៩. ការផ្លាស់ទីកន្លែងដោយបង្ខំ

ករណីវិវាទដីធ្លីធ្ងន់ធ្ងរ ប្រពលរដ្ឋរងគ្រោះត្រូវបានចាប់ខ្លួន រងការគំរាមកំហែង និងបង្ខំឲ្យចេញពីលំនៅឋាន ក្នុងនោះវិវាទចំនួន ៦៩ករណី ប្រជាពលរដ្ឋរងគ្រោះត្រូវបានបង្ខំឲ្យចេញពីលំនៅឋាន។ មានមូលហេតុជាច្រើនដែលពាក់ព័ន្ធទៅនឹងការបង្ខំឲ្យប្រជាពលរដ្ឋរងគ្រោះចេញពីលំនៅឋាន ដូចជា ការផ្តល់សម្បទានដីសេដ្ឋកិច្ច ការរៀបចំទីតាំងបន្ទាយទាហាន ការវិនិយោគរបស់ក្រុមហ៊ុនឯកជន តំរូវការដីសំរាប់ការដាំដុះ តំរូវការដីសំរាប់លំនៅឋាន ការផ្តល់ដីសម្បទានសង្គមកិច្ច ដីតំបន់អភិវឌ្ឍន៍របស់រដ្ឋ និងការទាមទារដីរបស់រដ្ឋជាកម្មសិទ្ធឯកជន។

វិវាទដីធ្លីចំនួន ៣១ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច បានបង្ខំឲ្យប្រជាពលរដ្ឋរងផលប៉ះពាល់ចេញពីតំបន់វិវាទ កើតមាននៅ ១៧ខេត្ត ដែលខេត្តព្រះវិហារ គឺជាខេត្តដែលមានវិវាទដីធ្លីខ្ពស់ជាងគេ ចំនួន ១១ករណី បន្ទាប់មកគឺខេត្ត

កំពង់ស្ពឺ និងខេត្តមណ្ឌលគីរី មាន ៤ករណីដូចគ្នា ខេត្តកោះកុងនិងខេត្តរតនគិរី ៣ ករណីដូចគ្នា ខេត្តក្រចះ មាន ២ករណី ខេត្តកំពង់ធំ ឧត្តរមានជ័យ ពោធ៍សាត់ និង ខេត្តព្រះសីហនុ មាន ១ករណីដូចគ្នា។

ជាសរុបប្រជាពលរដ្ឋ ចំនួន ១០,១១៣.០០គ្រួសារ ស្មើរនឹង១៦,៧១១.០០នាក់[21] រងផលប៉ះពាល់និងត្រូវបានបង្ខំឲ្យចាកចេញ។ ដោយឡែកនៅក្នុងឆ្នាំ២០១៥ មានករណីវិវាទដីធ្លីក្នុងខេត្តចំនួន៣ ដែលប្រជាពលរដ្ឋរងគ្រោះត្រូវបានបង្ខំឲ្យចេញពីលំនៅឋាន។ ខេត្តទាំងបីនោះ មានដូចជា ខេត្តបាត់ដំបង ខេត្តក្រចេះ និងខេត្តព្រះវិហារ។



រូបទី ១០: សម្បទានដីសេដ្ឋកិច្ចទាក់ទិននឹងការផ្លាស់ទីកន្លែងដោយបង្ខំ ឆ្នាំ ២០០៧-២០១៥

[21] ទិន្នន័យជាក់ស្តែងនៅក្នុងមូលដ្ឋានទិន្នន័យ។

ក្នុងចំណោមវិវាទដីធ្លីចំនួន ៥៩ករណី ដែលមានការផ្លាស់ទីកន្លែងដោយបង្ខំ មាន១៤ករណី ជាប្រជាពលរដ្ឋជនជាតិដើមភាគតិចនៅក្នុងខេត្តចំនួន៦ គឺខេត្តមណ្ឌលគិរីមាន៤ករណី ខេត្តព្រះវិហារមាន៤ករណី ខេត្តកំពង់ស្ពឺមាន២ករណី ខេត្តរតនៈគិរីមាន២ករណី ខេត្តក្រចេះ១ករណី និងខេត្តពោធិសាត់មាន១ករណី។ ករណីទាំងនោះបង្ករឡើងដោយក្រុមហ៊ុនចិន ក្រុមហ៊ុនវៀតណាម និងក្រុមហ៊ុនខ្មែរ ក្នុងនោះមានក្រុមហ៊ុនខ្មែរចំនួន៧ មានដូចជា ក្រុមហ៊ុនភ្នំពេញស៊ូហ្គ័រ(Phnom Penh Sugar) នៅក្នុងខេត្តកំពង់ស្ពឺ ក្រុមហ៊ុនឌីធីសីក្រុប(D.T.C Group) និងក្រុមហ៊ុនសុខហ្វីន ខេស៊ីឌី (Sok Fine KCD ពីមុនឈ្មោះ កូរីហ្គាមា ខូអិលធីឌី) នៅក្នុងខេត្តមណ្ឌលគិរី ក្រុមហ៊ុនទ្រីភាព (Try Pheap company) ក្រុមហ៊ុនស្រីបញ្ញា (Srey Panha) នៅក្នុងខេត្តព្រះវិហារ ក្រុមហ៊ុនអ៊ឹមឌីអេស អិមជត អិចជត ខូអិលធីឌី (MDS Import Export Co.,Ltd)នៅក្នុងខេត្តពោធ៍សាត់ និងក្រុមហ៊ុនអិមឌីគ្រុប (DM Group) នៅក្នុងខេត្តរតនៈគិរី។ ជាមួយគ្នានេះ ក្រុមហ៊ុនចិនចំនួន៣ មានដូចជា ក្រុមហ៊ុនវូជីសាន អិលអេសក្រុប ខូអិលធីឌី (Wuzhishan L.S Group Co.Ltd) នៅក្នុងខេត្តមណ្ឌលគិរី ក្រុមហ៊ុនហេងយូខេមបូឌា (Heng You Cambodia Company) ក្រុមហ៊ុនឡានហ្វេង (ខេមបូឌា) អ៊ុនធីណេសិនណល លីមីតធីត (Lan Feng (Cambodia) International Campany Limited) និងក្រុមហ៊ុនរ៉ូយហ្វេង ខេមបូឌា (Ruy Feng Cambodia) នៅក្នុងខេត្តព្រះវិហារ។ ក្រុមហ៊ុនវៀតណាមពីរទៀត មានដូចជា ក្រុមហ៊ុនបិញហ៊ឹកក្រចេះរ៉ាបប័រ១ (Benh Hoeurk Kratie Rubber 1 Company Limited) និងក្រុមហ៊ុនហេងប្រារដ័រ (Heng Brother) នៅក្នុងខេត្តរតនៈគិរី។ មានក្រុមហ៊ុនចំនួនពីរទៀត មិនអាចកំណត់អត្តសញ្ញាណបាន។

ករណីមួយ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដែលវិនិយោគលើដំណាំអំពៅ នៅក្នុងខេត្តកំពង់ស្ពឺ មានឈ្មោះថាក្រុមហ៊ុនភ្នំពេញស៊ូហ្គ័រ មានលោក លី យ៉ុងផាត់ ជាម្ចាស់ក្រុមហ៊ុន។ នៅក្នុងឆ្នាំ២០១០ មានប្រជាពលរដ្ឋចំនួន ១,៥០០.០០គ្រួសារ រងផលប៉ះពាល់និងត្រូវបានបង្ខំឲ្យចេញពីតំបន់វិវាទ នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

ប្រជាពលរដ្ឋរង ធ្លាប់បង្ករបង្កើនផលនៅតំបន់វិវាទតាំងឆ្នាំ១៩៧៩ ក្រោយសម័យប៉ុលពត មកម្ល៉េះ។ ក្រោមការតវ៉ាអស់រយៈពេលជាច្រើនឆ្នាំ គ្រួសាររងគ្រោះបានឯកភាពទទួលសំណងជាកញ្ចប់ពីក្រុមហ៊ុន ដោយមានគ្រួសារជាច្រើនព្រមទទួលសំណង ៥០០ដុល្លាអាមេរិចក្នុងមួយគ្រួសារ។

ករណីមួយផ្សេងទៀត ជាវិវាទដីធ្លីរវាងប្រជាពលរដ្ឋចំនួន ៤៥គ្រួសារ ជាមួយក្រុមហ៊ុនហេងយូខេមបូឌា (Heng You Cambodia) នៅភូមិសង្កែ ឃុំសង្កែមួយ ស្រុកឆែប នៅក្នុងខេត្តព្រះវិហារ។ នៅក្នុងឆ្នាំ២០១៤ អាជ្ញាធរបានបង្ខំប្រជាពលរដ្ឋមូលដ្ឋានឲ្យចេញពីដីរបស់ពួកគេ និងមិនអនុញ្ញាតិឲ្យចូលទៅដាំដុះបង្ករបង្កើនផលឡើយ។ ករណីនេះមានការគំរាមកំហែងដល់សកម្មជនដីធ្លី ហើយករណីនេះនៅតែមិនទាន់បានដោះស្រាយនៅឡើយ។

១០. បទពិសោធន៍នៃដំណោះស្រាយល្អៗ

ឆ្លងកាត់តាមការអង្កេត មានវិធីស្រាស្ត្រផ្សេងៗគ្នាពីករណីមួយទៅករណីមួយ បានប្រើប្រាស់ក្នុងការដោះស្រាយវិវាទដីធ្លីកន្លងមក។ ក្នុងឆ្នាំ២០១៥ វិវាទដីធ្លីដែលបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដំណោះស្រាយត្រូវបានធ្វើឡើងតាមរយៈការបង្កើតជាគណៈកម្មការដោះស្រាយ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន មន្ទីពាក់ព័ន្ធនៅក្នុងខេត្ត និងពេលខ្លះក៏មានការចូលរួមពីថ្នាក់ក្រសួងនានាផងដែរ។ ការអនុវត្តបទបញ្ជា០១ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទទួលបន្ទុកក្នុងការដោះស្រាយវិវាទ ដែលក្រុមការងារនេះ ហាក់ដូចជាមានអំណាចក្នុងការដោះស្រាយវិវាទដីធ្លីមានលក្ខណៈឆាប់រហ័ស បើទោះបីជាការអនុវត្តចំនុចខ្លះមានចន្លោះប្រហោងក្តី។

ករណីមួយ អាជ្ញាធរខេត្តផ្ទាល់ ដើរតួជាអ្នកសម្របសម្រួលភាគីវិវាទ ក្នុងការជជែកវែកញ្ច៉ែករកដំណោះស្រាយ។ ជាឧទាហរណ៍ ករណីលេខ២២៤៨ ជាវិវាទរវាង

ក្រុមហ៊ុនសីលាដាម៉ុច (Seila Damix) ក្នុងខេត្តព្រះវិហារ ជាមួយប្រជាពលរដ្ឋ ដែលអភិបាលរងខេត្ត រួមជាមួយប្រធានមន្ទីរៀបចំដែនដី ប្រធានរដ្ឋបាលព្រៃឈើ និងមន្ត្រីពាក់ព័ន្ធមួយចំនួន បានចុះទៅដល់ទីកន្លែងកើតហេតុ ហើយបានសម្របសម្រួលកិច្ចប្រជុំរវាងតំណាងក្រុមហ៊ុន និងប្រជាពលរដ្ឋ។ ជាលទ្ធផលយើងឃើញថាក្រុមហ៊ុនបានយល់ព្រមបញ្ឈប់ជម្លោះ ដោយប្រើរូបមន្តស្បែកខ្លាឃ្វាលចេញនូវដីប្រជាពលរដ្ឋដែលកំពុងកាន់កាប់ជាក់ស្តែង។

ករណីមួយទៀត វិវាទលើស្រះទឹកសាធារណៈនៅភូមិព្រៃធំ ឃុំគោខ្ចាក់ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ជាស្រះទឹកដែលកេណ្ឌប្រជាជនឲ្យជីកក្នុងសម័យប៉ុលពតសំរាប់ប្រើប្រាស់ជាផលប្រយោជន៍រួម ក្រោយឆ្នាំ១៩៧៩ ត្រូវបានប្រើប្រាស់ជាសម្បត្តិសាធារណៈសំរាប់មនុស្ស សត្វពាហនៈ និងបូមស្រោចស្របស្រូវ និងពុំដែលមានភាគីណាមកទាមទារជាកម្មសិទ្ធិឯកជនទេ។ លុះមកដល់ថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៩ គណៈកម្មការរដ្ឋបាលនៃដំណើការក្នុងការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធបានវាស់វែងដើម្បីចេញប័ណ្ណកម្មសិទ្ធិជូនពលរដ្ឋ។ ពេលនោះឈ្មោះ ចាប់ សុជាត ជាមេភូមិព្រៃធំ ឃុំគោកខ្ចាក់ បានដកយកដីស្រះទឹកទំហំ ១៩ម គុណ ៤ម ជាកម្មសិទ្ធិរបស់ខ្លួន។ ប្រជាពលរដ្ឋ មានការជំទាស់ ហើយគណៈកម្មការរដ្ឋបាល បានអញ្ជើញភាគីទាំងពីរមកធ្វើការសម្រុះសម្រួលគ្នានៅកន្លែងកើតហេតុ ប៉ុន្តែមិនអាចដោះស្រាយបាន ហើយករណីនេះ បានបង្កកចោលនៅសុរិយោដីខេត្តព្រៃវែង។ ក្រោយមកអាជ្ញាធរឃុំ បានប្រើអាណត្តិរបស់ខ្លួន ក្នុងការដោះស្រាយដោយបានសំរេចទុកស្រះទឹកទំហំ ៧៦ម៉ែត្រការ៉េនេះ ជាសម្បត្តិសាធារណៈដដែលដើម្បីឲ្យប្រជាជនប្រើប្រាស់រួមដូចពីមុន។

១១. សេចក្តីសន្និដ្ឋាន

យោងទៅលើលទ្ធផលនៃការវិភាគស្ថិតិខាងលើ យើងសង្កេតឃើញមាននូវនិន្នាការមួយចំនួន ដូចខាងក្រោម៖

ចំនួនវិវាទដីធ្លី៖ ចំនួនវិវាទដីធ្លីដែលកើតថ្មីក្នុងឆ្នាំ២០១៥ មានចំនួន ២៣ករណី។ ចំនួននេះស្មើនឹងចំនួនវិវាទកើតថ្មីក្នុងឆ្នាំមុន ប៉ុន្តែទាបជាងករណីវិវាទកើតឡើងថ្មីៗក្នុងបណ្តាឆ្នាំ២០១០ ២០១១ ២០១២ និង២០១៣។

ខេត្តដែលរងផលប៉ះពាល់ពីវិវាទដីធ្លី៖ វិវាទដីធ្លីកើតមានក្នុងបណ្តាខេត្តទូទាំងប្រទេស។ រាជធានីភ្នំពេញ គឺជាកន្លែងដែលមានវិវាទដីធ្លីកើតខ្ពស់ជាងគេ ដែលមានវិវាទចំនួន ២៥ករណី ខណៈដែលខេត្តរតនគិរី ស្ថិតក្នុងលំដាប់ទីពីរ មានវិវាទចំនួន ២២ករណី ។

ករណីវិវាទដែលបានដោះស្រាយគិតតាមឆ្នាំ៖ សំរាប់ឆ្នាំ២០១៥ មានវិវាទចំនួន ២១ករណី បានដោះស្រាយចប់ពេញលេញទាំងស្រុង និងមានវិវាទចំនួន ២៨៥ករណី កំពុងបន្តដោះស្រាយ និងរងចាំដំណោះស្រាយ។ ករណីដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១៥ ស្មើរនឹងពាក់កណ្តាល ករណីវិវាទដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១៤។ នៅក្នុងឆ្នាំ ២០១៥ មានករណីវិវាទដីធ្លីចំនួន ១៥៤ករណី មិនទាន់បានដោះស្រាយ ខណៈវិវាទដីធ្លីចំនួន ១២៤ករណី បានដោះស្រាយដោយផ្ទែក។ វិវាទដីធ្លីចំនួន ២ករណី ឬស្មើរនឹង០.៦ ភាគរយនៃចំនួនករណីវិវាទសរុប បានបោះបង់ចោលដោយភាគីវិវាទ។ ចំណែកឯវិវាទដីធ្លីចំនួន ៧ករណី ឬស្មើរនឹង២.២ភាគរយនៃវិវាទសរុបមានសភាព"ស្ងៀមស្ងាត់" ។

ស្ថាប័នដែលទទួលពាក្យបណ្តឹង៖ វិវាទចំនួន ៣០៨ករណី បានដាក់ពាក្យបណ្តឹងចំនួន ៨៨១បណ្តឹង ទៅកាន់ស្ថាប័ននានា ចាប់ពីកំរិតអាជ្ញាធរមូលដ្ឋាន រហូត

ដល់កំរិតថ្នាក់ជាតិ។ ក្នុងឆ្នាំ២០១៥ វិវាទចំនួន ២១ករណី ដែលបានដោះស្រាយចប់ពេញលេញទាំងស្រុង មានវិវាទចំនួន ១២ករណី ដែលគណៈកម្មការចម្រុះខេត្តដោះស្រាយ ក្នុងនោះក៏មានការចូលរួមចំណែកមួយភាគធំ ចេញពីការអនុវត្តបទបញ្ជា០១ ផងដែរ ដោយបានអនុវត្តក្នុងឆ្នាំ២០១២ និង២០១៣។ អាជ្ញាធរមូលដ្ឋានឃុំ ក៏បានដោះស្រាយចប់ពេញលេញទាំងស្រុង នូវវិវាទចំនួន ៣ករណីផងដែរ។

<u>គ្រួសារដែលរងផលប៉ះពាល់ពីវិវាទដីធ្លី៖</u> វិវាទដីធ្លីចំនួន ២៨៥ករណី កំពុងបន្តដោះស្រាយ និងរងចាំដំណោះស្រាយ បានប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៥៨,០៥១.០០គ្រួសារ ឬស្មើរនឹង២២១,០៣៥.០០នាក់។ នៅរាជធានីភ្នំពេញមានប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារវិវាទដីធ្លីខ្ពស់ជាងគេ មានចំនួន ៦,០៧៨.០០ គ្រួសារ ហើយបន្ទាប់នោះគឺខេត្តព្រៃវែងមាន ៥,៥០១.០០គ្រួសារ។

<u>ប្រភេទដីដែលរងផលប៉ះពាល់ពីទំនាស់ដីធ្លី៖</u> វិវាទដីធ្លីបានគ្រប់ដណ្តប់លើផ្ទៃដីចំនួន ៩៩៥,០១៧.៦០ហិចតា។ ផ្ទៃដីដែលមានវិវាទទាំងនោះ មានប្រភេទផ្សេងគ្នា រួមមាន ដីកសិកម្ម(ដីចំការ និងដីស្រែ) ដីលំនៅឋាន/ភូមិករ ដីរដ្ឋ(ដែលបញ្ចូលទាំងដីព្រៃសហគមន៍ ដីព្រៃ ដីច្រាំងទន្លេ ដីព្រៃលិចទឹក ស្រះទឹករួម ដីសាលារៀន ដីឆ្នេរប្រឡាយ/ចំណីប្រឡាយ ផ្លូវថ្មើរជើង ដីគ្រោងសម្រាប់ការពង្រីកប្រឡាយឬផ្លូវ ដីកប់ខ្មោចរបស់ជនជាតិដើមភាគតិច និងដីរួមរបស់ភូមិ/ឃុំ) ដីវត្ត និងដីប្រើប្រាស់សម្រាប់គោលបំណងច្រើនយ៉ាង។ ដីលំនៅឋាន/ដីភូមិ គឺជាប្រភេទដីដែលជាកម្មវត្ថុនៃវិវាទដីធ្លីច្រើនជាងគេ ដោយផ្ទៃដីសរុបមានចំនួន ៧៩១,០៣៥.៩០ហិកតា បន្ទាប់មកគឺដីប្រើប្រាស់សម្រាប់គោលបំណងច្រើនយ៉ាង ដោយផ្ទៃដីសរុបមានចំនួន១២៣,២៨១.០០ ហិកតា។

<u>មូលហេតុនៃទំនាស់ដីធ្លី៖</u> ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺជាមូលហេតុធំបំផុតនៃវិវាទដីធ្លី ដោយមាន ៩៧ក្រុមហ៊ុន បាននិងកំពុងបង្កឲ្យមានវិវាទដីធ្លីនៅ១៨ ខេត្ត។ វិវាទដីធ្លីចំនួន ៥២ករណី បានបង្កដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបាន

ប្រើប្រាស់អំណាចក្នុងការរំលោភយកដី ៣០ករណីមានប្រើអំពើហឹង្សា ២២ករណីមានជាប់ពាក់ព័ន្ធជាមួយអាជ្ញាធរ និង២០ករណីមានការចាប់ខ្លួនប្រជាពលរដ្ឋ (ករណីខ្លះមានរងនូវការប្រើប្រាស់អំពើហឹង្សា ការប្រើប្រាស់អំណាចក្នុងការរំលោភយកដី និងជាប់ពាក់ព័ន្ធជាមួយអាជ្ញាធរ ព្រមទាំងការបាច់ខ្លួនប្រជាពលរដ្ឋ) ។

<u>ឯកសារនិងវិធីសាស្ត្រប្រើប្រាស់ដោយភាគីវិវាទ៖</u> ឯកសារដែលប្រើប្រាស់ ជាការសំអាងក្នុងការទាមទារដីដោយភាគីទាំងសងខាង នៃវិវាទ រួមមាន ការសំអាងតាមរយៈការតាំងលំនៅឋានមិនរៀបរយ សិទ្ធិជាប្រពៃណីជនជាតិដើមភាគតិច លិខិតទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច កិច្ចសន្យារុករករ៉ែ ឯកសារកម្មសិទ្ធិមិនផ្លូវការ ផែនទីគម្របព្រៃឆ្នាំ២០០២ និងការដឹងឮដោយប្រជាជនដែលរស់នៅជុំវិញ។

<u>ការកាន់កាប់លើដីទំនាស់៖</u> វិវាទដីធ្លីចំនួន៩២ករណី ស្មើរនឹង៣២ភាគរយនៃករណីកំពុងបន្តដោះស្រាយ និងរងចាំដំណោះស្រាយ ត្រូវបានកាន់កាប់ដោយអ្នកកាន់កាប់ដើម។ វិវាទចំនួន ៨៣ករណី ស្មើរនឹង ២៩ភាគរយ កំពុងកាន់កាប់ដោយភាគីទីពីរ វិវាទចំនួន ៦១ករណី ស្មើរនឹង២១ភាគរយ កំពុងកាន់កាប់ដីដោយភាគីទាំងសងខាង និងវិវាទចំនួន៥០ករណី ស្មើរនឹង១៧ភាគរយ មិនមានព័ត៌មានអំពីស្ថានភាពនៃការកាន់កាប់។

វិវាទចំនួន ៩៧ករណី បង្កដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច កំពុងបន្តដោះស្រាយ និងរងចាំដំណោះស្រាយ។ ក្នុងនោះមាន ២៩ករណី កំពុងកាន់កាប់ដោយភាគីចុងបណ្តឹងជា"ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច" ដោយដីវិវាទសរុបទំហំ ៥៦,០៣៥.០០ហិកតា ប៉ះពាល់ប្រជាពលរដ្ឋចំនួន ៥,១៩៥.០០គ្រួសារ។ ភាគច្រើនវិវាទដីធ្លីទាំងនោះ គឺជាដីកសិកម្មដែលជាប្រភពចំណូលចំបងរបស់ប្រជាពលរដ្ឋ។ វិវាទចំនួន ២៦ករណី ត្រូវបានកាន់កាប់ដោយអ្នកកាន់កាប់ដីដើមដែលជា "ប្រជាពលរដ្ឋមូលដ្ឋាន"។ វិវាទចំនួន ២៤ករណី កាន់កាប់ដោយភាគីទាំងសងខាងនៃវិវាទ

និងវិវាទចំនួន ១២ករណីទៀត មិនមានព័ត៌មានអំពីស្ថានភាពនៃការកាន់កាប់ដី។

ទំនាស់ដីធ្លីបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ច៖ វិវាទដីធ្លីចំនួន ៩៧ករណី ដោយបញ្ចូលទាំងករណីបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១៥ ឬស្មើរ៣៣.៧៦ភាគរយនៃករណីវិវាទសរុប បានបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច កើតមាននៅក្នុងខេត្តចំនួន១៨ ភាគច្រើនកើតមាននៅក្នុងខេត្តភាគឦសាននៃប្រទេស។ ខេត្តរតនគិរី គឺជាខេត្តមានវិវាទដីធ្លីបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចខ្ពស់ជាងគេ មានចំនួន ១៥ករណី បន្ទាប់ខេត្តមណ្ឌលគិរី មានចំនួន ១៣ករណី។

ទំនាស់ដីធ្លីបង្ករផលប៉ះពាល់លើជនជាតិតដើមភាគតិច៖ ប្រមាណជា ១៧.៨ ភាគរយ ស្មើរនឹង៥១ករណី ក្នុងចំណោមវិវាទដីធ្លីដែលកំពុងបន្តដោះស្រាយ និងរងចាំដំណោះស្រាយ បានកំពុងប៉ះពាល់ដល់ប្រជាពលរដ្ឋ ជាជនជាតិដើមភាគតិចនៅក្នុងខេត្តចំនួន ៨ខេត្ត ដូចជា ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ ខេត្តពោធិ៍សាត់ ខេត្តរតនគិរី និងខេត្តព្រះសីហនុ។ វិវាទដីធ្លីចំនួន ៣៥ករណី បង្ករផលប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ក្នុងនោះខេត្តដែលរងផលប៉ះពាល់ខ្ពស់ជាង គឺខេត្តរតនគិរីមានចំនួន ១៣ករណី និងខេត្តមណ្ឌលគិរីមានចំនួន ១៣ករណី ខេត្តកំពង់ស្ពឺ ៥ករណី ខេត្តព្រះវិហារ ៣ករណី ខេត្តក្រចេះ ២ករណី ខេត្តពោធិ៍សាត់ ១ករណី និងខេត្តព្រះសីហនុ ១ករណី។

ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ៖ វិវាទចំនួន ៦៩ករណី បានបង្ខំឲ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់ឲ្យចេញពីលំនៅឋាន ដោយមានមូលហេតុជាច្រើនមានដូចជា ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការរៀបចំទីតាំងបន្ទាយទាហាន ការវិនិយោគរបស់ក្រុមហ៊ុនឯកជន តំរូវការដីសំរាប់ការដាំដុះ តំរូវការដីលំនៅឋាន ការផ្តល់សម្បទានដីសង្គមកិច្ច តំបន់អភិវឌ្ឍន៍របស់រដ្ឋ និងការកាន់កាប់ដីរបស់រដ្ឋជាកម្មសិទ្ធឯកជន។

<u>បទពិសោធន៍ដំណោះស្រាយល្អៗ៖</u> ឆ្លងកាត់តាមការអង្កេត មានវិធីស្រាស្រ្តផ្សេងៗគ្នាពីករណីមួយទៅករណីមួយ បានប្រើប្រាស់ក្នុងការដោះស្រាយវិវាទដីធ្លីកន្លងមក។ ក្នុងឆ្នាំ២០១៥ វិវាទដីធ្លីដែលបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដំណោះស្រាយត្រូវបានធ្វើឡើងតាមរយៈការបង្កើតជាគណៈកម្មការដោះស្រាយដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន មន្ទីពាក់ព័ន្ធនៅក្នុងខេត្ត និងពេលខ្លះក៏មានការចូលរួមពីថ្នាក់ក្រសួងនានាផងដែរ។ ការអនុវត្តបទបញ្ជា០១ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ទទួលបន្ទុកក្នុងការដោះស្រាយវិវាទ ដែលក្រុមការងារនេះ ហាក់ដូចជាមានអំណាចក្នុងការដោះស្រាយវិវាទដីធ្លីមានលក្ខណៈឆាប់រហ័ស បើទោះបីជាការអនុវត្តចំនុចខ្លះមានចន្លោះប្រហោងក្តី។